ខុមហ្វ្រែល COMFREL

# របាយការណ៍
# សង្កេតរដ្ឋសភា និងតំណាងរាស្ត្រ

## របាយការណ៍ឆ្នាំទី១ នីតិកាលទី៦ (កញ្ញា ២០១៨ - សីហា ២០១៩)




ខែមីនា ឆ្នាំ ២០២០

## មាតិកា


សង្ខេបការរកឃើញ........................................................................................ 1

សន្និដ្ឋាន ....................................................................................................... 3

វិធីសាស្រ្តក្នុងការប្រមូលទិន្នន័យសម្រាប់ចងក្រងរបាយការណ៍ ........................................... 4

របាយការណ៍ស្តីពីការសង្កេតរដ្ឋសភាជាតិ ......................................................... 5

ក្នុងឆ្នាំទី១ នីតិកាលទី៦ (២០១៩)........................................................................ 5

១. ដំណើរការសម័យប្រជុំនៃរដ្ឋសភា ............................................................... 6

១.១. ចំនួនកិច្ចប្រជុំរដ្ឋសភាពេញអង្គ ........................................................... 7

១.២. ការបញ្ចេញមតិរបស់អ្នកតំណាងរាស្រ្តក្នុងសម័យប្រជុំ ................................... 11

២.ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្រ្ត.............................................................. 15

២.១. ចំនួនដង និងចំនួនអ្នកតំណាងរាស្រ្តចុះមូលដ្ឋាន ........................................ 16

២.២ គោលបំណងរបស់តំណាងរាស្រ្តចុះមូលដ្ឋាន.................................................. 17

២.៣.មណ្ឌលរាជធានី ខេត្ត ដែលតំណាងរាស្រ្តបានចុះបេសកកម្ម ............................. 23

៣. គណៈកម្មការជំនាញនៃរដ្ឋសភា ................................................................... 25

៣.១ គោលបំណងនៃការចុះបេសកកម្មរបស់គណៈកម្មការជំនាញ................................ 27

៤. ការវិភាគសកម្មភាពរបស់តំណាងរាស្រ្ត .......................................................... 32

៥. រដ្ឋសភាឯកបក្ស........................................................................................ 35

៥.១. នីតិកាលទី៦ រដ្ឋសភាមិនមានការចម្រូងចម្រាស............................................. 36

៦. កាលប្បវត្តិព្រឹត្តិការណ៍សំខាន់ៗ នៃរដ្ឋសភាជាតិ.................................................. 37

Vision: A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ថ្ងៃពុធ ៦កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# របាយការណ៍សង្ខេបនៃការសង្កេតរដ្ឋសភា និងតំណាងរាស្ត្រ ឆ្នាំទី១ នៃនីតិកាលទី៦

ក្នុងនីតិកាលទី៦ រដ្ឋសភាមានបក្សតែមួយគឺគណបក្សប្រជាជនកម្ពុជា និងជាគណបក្សកាន់អំណាចបច្ចុប្បន្ន។ របាយការណ៍សង្កេតរដ្ឋសភា និងតំណាងរាស្ត្រ នៃរដ្ឋសភាឆ្នាំទី១ នីតិកាលទី៦ ឆ្នាំ២០១៩ ខុមហ្វ្រែលបានសង្កេតឃើញថា សកម្មភាពនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ក្នុងគោលបំណង ដើម្បីសំណេះសំណាលជាមួយប្រជាពលរដ្ឋ ពង្រឹងផ្ទៃក្នុងរបស់គណបក្ស អមដំណើរថ្នាក់ដឹកនាំ គឺផុសផុល លើកលែងតែសកម្មភាពក្នុងគោលបំណងចុះជួយអន្តរាគមន៍ដោះស្រាយបញ្ហា ជាពិសេសទំនាស់ដីធ្លីជូនប្រជាពលរដ្ឋ មិនត្រូវបានសង្កេតឃើញ មានតំណាងរាស្ត្រខ្នះខ្នែង ឬយកចិត្តទុកដាក់ជួយដោះស្រាយនោះទេ។ ដោយឡែក សម័យប្រជុំរដ្ឋសភាក្នុងឆ្នាំទី១ នៃនីតិកាលទី៦ រដ្ឋសភាបានបើកសម័យប្រជុំទាំងសាមញ្ញ និងវិសាមញ្ញ ភាគច្រើនគឺផ្តោតលើការអនុម័តច្បាប់។ អ្វីដែលខុមហ្វ្រែលបានសង្កេតឃើញក្នុងសម័យប្រជុំ តំណាងរាស្ត្របានឡើងបញ្ចេញមតិក្នុងការអនុម័តច្បាប់នានា ភាគច្រើនបំផុតក្នុងសម័យប្រជុំទាំងនោះ មិនសូវមានឃើញតំណាងរាស្ត្រណាម្នាក់ជំទាស់ រិះគន់ ឬសួរដេញដោលដោយស៊ីជម្រៅឡើយ ផ្ទុយមកវិញគឺមានតែការកោតសសើរ និងគាំទ្រដល់ការដឹកនាំរបស់រាជរដ្ឋាភិ បាលតែប៉ុណ្ណោះ។ ដោយឡែកសកម្មភាពរបស់គណៈកម្មការជំនាញរបស់រដ្ឋសភាមានសកម្មភាពជាច្រើនផងដែរ តែចំពោះការកោះហៅសមាជិករាជរដ្ឋាភិបាលនៅក្នុងឆ្នាំទី១នេះ មានតែម្តងគត់គឺ ការកោះហៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មកសារសួរ។ ការសាកសួរនេះ តំណាងរាស្ត្រមិនបានឱ្យរដ្ឋមន្ត្រីធ្វើការបកស្រាយអំពីសកម្មភាពកន្លងមកដែលមតិជាតិ និងអន្តរជាតិយល់ថាជាភាពអយុត្តិធម៌នៅប្រទេសកម្ពុជាឡើយ បែរជាឱ្យរដ្ឋមន្ត្រីជួយបំភ្លឺអំពីការងារដែលសម្រេចបាន និងផែនការដែលត្រូវធ្វើទៅថ្ងៃខាងមុខទៅវិញ។ មួយវិញទៀត ការយកចិត្តទុកដាក់ចំពោះប្រជាពលរដ្ឋ ដោយជួយខ្នះខ្នែងការពារយុត្តិធម៌ ការពារផលប្រយោជន៍ និងភាពជាតំណាងក្នុងកិច្ចការផ្សេងៗ របស់ប្រជាពលរដ្ឋ ដែលជាការងារចម្បងរបស់តំណាងរាស្ត្រត្រូវយកចិត្តទុកដាក់បំផុតនោះ ខុមហ្វ្រែលសង្កេតមិនទាន់ឃើញថា មានអ្នកតំណាង រាស្ត្រណាម្នាក់ចេញលិខិតអន្តរាគមន៍ជួយប្រជាពលរដ្ឋនូវឡើយ បើទោះបីជាប្រជាពលរដ្ឋទាំងនោះទាមទារសុំអន្តរាគមន៍រកយុត្តិធម៌ក៏ដោយ។

ជារួម នៅក្នុងឆ្នាំទី១ នៃនីតិកាលទី៦នេះ ខុមហ្វ្រែលបានសង្កេតឃើញថា ប្រសិទ្ធភាពសភាឯកបក្សមានការធ្លាក់ចុះ បើប្រៀបជាមួយរដ្ឋសភាដែលធ្លាប់មានពហុបក្ស។ ការធ្លាក់ចុះនៃរដ្ឋសភាឯកបក្សនេះ ព្រោះមិនឃើញមានការចេញលិខិតអន្តរាគមន៍របស់តំណាងរាស្ត្រ មិនឃើញមានអ្នកតំណាងរាស្ត្រនិយាយពីភាពអសកម្មក្នុងការដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋ សកម្មភាពសួរដេញដោលលើការអនុវត្តិច្បាប់ និងសេចក្តីស្នើច្បាប់នៅក្នុងសម័យប្រជុំសភាផងដែរ។

**ដំណើរការប្រជុំពេញអង្គរបស់រដ្ឋសភា៖** ក្នុងឆ្នាំទី១ អាណត្តិទី៦ រដ្ឋសភាបានរៀបចំកិច្ចប្រជុំចំនួន ១១ដង ដោយសម្រេចបាននូវរបៀបវារៈចំនួន ២៩។ ក្នុងរបៀបវារៈដែលបានពិភាក្សា និងអនុម័តភាគច្រើនគឺសេចក្តីព្រាងច្បាប់ដែលមានចំនួន ១៤ រួមមានការអនុម័តច្បាប់ទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ និងអនុម័តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។ រដ្ឋសភាក៏បានធ្វើការអនុម័តលើការធ្វើវិសោធនកម្មច្បាប់ធំៗ ចំនួន៣ ដោយឯកបក្សផងដែរ ក្នុងនោះរួមមានច្បាប់គណបក្សនយោបាយ និងច្បាប់បោះឆ្នោតចំនួន ២ទៀត។

ក្នុងសម័យប្រជុំរបស់រដ្ឋសភាឆ្នាំទី១ នៃសភាឯកបក្សនេះ ខុមហ្វ្រែល បានសង្កេតឃើញមានតំណាងរាស្ត្រចំនួន ១២រូប បានឡើងបញ្ចេញមតិចំនួន ៣៨ដង គិតជាថេរៈវេលាមានរយៈពេល ២០៩នាទី បើគិតពីចំនួនអ្នកតំណាងរាស្ត្រ និងរយៈពេលតិចជាង បើប្រៀបធៀបជាមួយឆ្នាំទី១ ដូចគ្នានៃអាណត្តិទី៥។

**សកម្មភាពចុះមូលដ្ឋានរបស់តំណាងរាស្ត្រ៖** ក្នុងឆ្នាំទី១ នៃនីតិកាលទី៦នេះ ក្នុងចំណោមតំណាងរាស្ត្រ ១២៥រូប មានតែអ្នកតំណាងរាស្ត្រ ៥៥រូប(៤៤ភាគរយ)ប៉ុណ្ណោះដែលមានសកម្មភាពចុះមូលដ្ឋាន។ សកម្មភាពចុះមូលដ្ឋាននេះ មានចំនួន ១០៤១លើក ដែលចំនួននេះ គិតជាមធ្យមគឺ ១៩លើក ក្នុងអ្នកតំណាងរាស្ត្រម្នាក់ដែលបានចុះបេសកកម្ម។ អ្នកតំណាងរាស្ត្រដែលបានចុះបេសកកម្មនេះ បើគិតជាភាគរយនៃចំនួនអ្នកតំណាងរាស្ត្រក្នុងបក្សរបស់ខ្លួនឃើញថាមានចំនួនចុះបេសកកម្មតិចជាងឆ្នាំទី១ នៃអាណត្តិទី៥ (៥០រូបស្មើនឹង៧៤ភាគរយ)។

ខុមហ្វ្រែល បានបែងចែកការចុះបេសកកម្មរបស់តំណាងរាស្ត្រក្នុងគោលបំណងចំនួន ៥ធំ។ ក្នុងចំណោមបេសកកម្ម ១០៤១លើកនេះ ៦៨ភាគរយ គឺជាការចុះសួរសុខទុក្ខ និងសំណេះសំណាល និងការសម្តែងការកោតសរសើរចំពោះអាជ្ញាធរមូលដ្ឋាន។ ទោះជាយ៉ាងណា ខុមហ្វ្រែល បានសង្កេតឃើញមានការចុះអន្តរាគមន៍ផងដែរ លើកលែងតែសកម្មភាពចូលរួមក្នុងវេទិកា ដែលមិនឃើញមាន។ តំណាងរាស្ត្របានចុះគ្រប់ ២៥រាជធានីខេត្ត ក្នុងនោះមាន ៤៥០លើក ជាបេសកកម្មនៅក្រៅមណ្ឌល និង ៥៩១លើក ជាបេសកកម្មនៅក្នុងមណ្ឌល។

**គណៈកម្មការជំនាញនៃរដ្ឋសភា៖** តាមការសង្កេតរបស់ខុមហ្វ្រែល ក្នុងចំណោមគណៈកម្មការជំនាញទាំង១០ របស់រដ្ឋសភាមានតែ ៨គណៈកម្មការជំនាញទេ ដែលបានធ្វើសកម្មភាព។ គណៈកម្មការ ដែលមិនមានសកម្មភាពនោះមានគណៈកម្មការទី៥ និងទី១០។ គណៈកម្មការជំនាញដែលបានធ្វើសកម្មភាពមានចំនួន ៩៨លើក។ ក្នុងចំណោមគណៈកម្មការដែលបានធ្វើសកម្មភាព មាន ៤គណៈកម្មការជំនាញដែលមានបេសកកម្មច្រើនជាងគេ ក្នុងនោះមាន គណៈកម្មការជំនាញទី៣ ទី៧ ទី៨ និងទី៩។

សកម្មភាពដែលគណៈកម្មការជំនាញចុះមូលដ្ឋាន ភាគច្រើនក្នុងគោលបំណងចុះដើម្បីស្វែងយល់មានចំនួន ៨៨លើក។ ការចុះសិក្សាស្វែងយល់នេះគឺ ចុះជួបជាមួយប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋានដើម្បីចូលរួមសិក្សាស្វែងយល់ពីបញ្ហានានា ដូចជាការអនុវត្តច្បាប់ និងការឆ្លើយតបដោយមានភាពយឺតយ៉ាវរបស់អាជ្ញាធរជាមួយប្រជាពលរដ្ឋ។

ខុមហ្វ្រែលក៏សង្កេតឃើញថាគណៈកម្មការជំនាញក្នុងឆ្នាំទី១ នៃអាណត្តិទី៦នេះ មានការកោះហៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មកសាកសួរផងដែរ តែទោះជាយ៉ាងណាការហៅសាកសួរនោះមិនបានផ្តោតលើបញ្ហាអយុត្តិធម៌ដែលបានកើតមាននៅក្នុងសង្គមខ្មែរនោះទេ ជាពិសេសប្រជាពលរដ្ឋដែលរងគ្រោះដោយបញ្ហាដីធ្លី ការកាប់ព្រៃឈើ ការប្រើប្រាស់កងកម្លាំងហួសហេតុក្នុងការដេញប្រជាពលរដ្ឋឱ្យរងរបួសដោយអនុវត្តសាលដីការបស់តុលាការកំពូលជាដើម។ល។

**ការវិភាគសកម្មភាពតំណាងរាស្ត្រ៖** ខុមហ្វ្រែលបានជ្រើសរើសសកម្មភាពរបស់តំណាងរាស្ត្រទាំង១០រូប ដែលមានសកម្មភាពសកម្មជាងគេតាមការសង្កេតក្នុងសម័យប្រជុំរដ្ឋសភា និងការចុះមូលដ្ឋាន។ ជាលទ្ធផលបានបង្ហាញថាតំណាងរាស្ត្រដែលមានតួនាទីជាសមាជិករដ្ឋាភិបាល ឬតួនាទីក្រៅពីស្ថាប័នរដ្ឋសភាបានចុះបេសកកម្មច្រើនជាងតំណាងរាស្ត្រមានតួនាទីក្នុងស្ថាប័នរដ្ឋសភា ក៏ប៉ុន្តែការបញ្ចេញមតិយោបល់ក្នុងសម័យប្រជុំសភា ខុមហ្វ្រែលសង្កេត

ឃើញថាអ្នកដែលមានមុខតំណែងក្នុងរដ្ឋាភិបាលបានបញ្ចេញមតិតិចតួច ឬមិនមានទាល់តែសោះ។ តំណាងរាស្ត្រដែលមានតួនាទីក្នុងរាជរដ្ឋាភិបាលមានដូចជា សម្តេចក្រឡាហោម ស ខេង តំណាងរាស្ត្រមណ្ឌលខេត្តបាត់ដំបង ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ សម្តេចពិជ័យសេនា ទៀ បាញ់ តំណាងរាស្ត្រមណ្ឌលខេត្តសៀមរាប ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ។ ឯកឧត្តម កែ គីមយ៉ាន តំណាងរាស្ត្រមណ្ឌលខេត្តបន្ទាយមានជ័យ ជាឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**សម្រាប់ព័ត៌មានបន្ថែម៖**

| **ឈ្មោះ** | | **លេខទូរស័ព្ទ** |
|---|---|---|
| • លោក **គឹម ឈន** | (នាយកប្រតិបត្តិ) | ០១២ ៩៤២ ០១៩ |
| • លោក **ភន សារ៉ាខន** | (អ្នកសម្របសម្រួលផ្នែកអង្កេត និងតស៊ូមតិ) | ០១១ ៨៨៤ ៨៤០ |

## សង្ខេបការរកឃើញ

ការបោះឆ្នោតថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ មានគណបក្សនយោបាយចំនួន ២០បានចូលរួមប្រកួតប្រជែង។ ការបោះឆ្នោតនេះ មិនមានវត្តមានគណបក្សសង្គ្រោះជាតិដែលជាដៃគូប្រកួតប្រជែងមួយដែលមានអ្នកគាំទ្រយ៉ាងធំចូលរួមប្រកួតប្រជែងនោះទេ ព្រោះតុលាការកំពូលបានសម្រេចរំលាយគណបក្សនេះមុនការបោះឆ្នោត និងបានហាមឃាត់អ្នកនយោបាយមកពីគណបក្សនេះចំនួន ១១៨រូបមិនអោយធ្វើនយោបាយរយៈពេលប្រាំឆ្នាំបន្ថែមទៀត។ ក្រោយការបោះឆ្នោតមានតែគណៈបក្សប្រជាជនតែមួយគត់ដែលទទួលបានកៅអីក្នុងរដ្ឋសភាចំនួន ១២៥អាសនៈ(១០០ភាគរយនៃចំនួនអាសនៈសរុប) ដែលនាំអោយគណបក្សប្រជាជនកម្ពុជាគ្រប់គ្រងស្ថាប័ននីតិប្រតិបត្តិ នីតិបញ្ញត្តិផ្តាច់ជាឯកបក្ស។

**ដំណើរការសម័យប្រជុំនៃរដ្ឋសភា៖** រដ្ឋសភាបានចាប់ផ្តើមសម័យប្រជុំដំបូងរបស់ខ្លួននៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៨ ក្រោមព្រះរាជាធិបតីភាពរបស់ព្រះមហាក្សត្រព្រះបាទសម្តេចព្រះនរោត្តម សីហមុនី។ ក្នុងឆ្នាំទី១ អាណត្តិទី៦ រដ្ឋសភាបានរៀបចំកិច្ចប្រជុំចំនួន ១១ដង ដោយសម្រេចបាននូវរបៀបវារៈចំនួន ២៩។ ក្នុងរបៀបវារៈដែលបានពិភាក្សា និងអនុម័តភាគច្រើនគឺសេចក្តីព្រាងច្បាប់ដែលមានចំនួន ១៤ រួមមានការអនុម័តច្បាប់ទូទាត់ថវិកាទូទៅរបស់រដ្ឋសភាសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ និងអនុម័តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។ រដ្ឋសភាក៏បានអនុម័តលើការធ្វើវិសោធនកម្មច្បាប់ធំចំនួន៣ ដោយឯកបក្សផងដែរ ក្នុងនោះរួមមានច្បាប់គណបក្សនយោបាយ និងច្បាប់បោះឆ្នោតចំនួន២ទៀត។

ក្នុងសម័យប្រជុំរបស់រដ្ឋសភា ឆ្នាំទី១ នៃសភាឯកបក្សនេះ ខុមហ្វ្រែល បានសង្កេតឃើញមានតំណាងរាស្ត្រចំនួន ១២រូប បានឡើងបញ្ចេញមតិចំនួន ៣៨ដង គិតជាថេរៈវេលាមានរយៈពេល ២០៩នាទី បើគិតពីចំនួនអ្នកតំណាងរាស្ត្រ និងរយៈពេលតិចជាង បើប្រៀបធៀបជាមួយឆ្នាំទី១ ដូចគ្នានៃអាណត្តិទី៥។

**ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ៖** ក្នុងឆ្នាំទី១ នៃនីតិកាលទី៦នេះ ក្នុងចំណោមតំណាងរាស្ត្រ១២៥រូប មានតែអ្នកតំណាងរាស្ត្រ ៥៥រូបប៉ុណ្ណោះដែលមានសកម្មភាពចុះមូលដ្ឋាន។ សកម្មភាពចុះមូលដ្ឋាននេះ មានចំនួន ១០៤១លើក ដែលចំនួននេះ គិតជាមធ្យមគឺអ្នកតំណាងរាស្ត្រម្នាក់ចុះបេសកកម្មបាន ១៩លើក។ អ្នកតំណាងរាស្ត្រដែលបានចុះបេសកកម្មនេះ បើគិតជាភាគរយនៃចំនួនអ្នកតំណាងរាស្ត្រក្នុងបក្សរបស់ខ្លួនឃើញថាមានចំនួនចុះបេសកកម្មតិចជាង កាលឆ្នាំទី១ នៃអាណត្តិទី៥។

ខុមហ្វ្រែល បានចែកការចុះបេសកកម្មរបស់តំណាងរាស្ត្រក្នុងគោលបំណងចំនួន ៥ធំ។ ក្នុងចំណោមបេសកកម្ម១០៤១លើកនេះ ៦៨.០ភាគរយ គឺជាការចុះសួរសុខទុក្ខ និងសំណេះសំណាល និងសម្តែងការកោតសរសើរចំពោះអាជ្ញាធរមូលដ្ឋាន។ ទោះជាយ៉ាងណា ខុមហ្វ្រែល បានសង្កេតឃើញមានការចុះអន្តរាគមន៍ផងដែរ លើកលែងតែសកម្មភាពចូលរួមក្នុងវេទិកា ដែលមិនឃើញមាន។

តំណាងរាស្ត្រមិនមែនតែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ គឺតំណាងប្រជាពលរដ្ឋទូទាំងប្រទេស។ តាមការសង្កេត តំណាងរាស្ត្របានចុះគ្រប់២៥រាជធានីខេត្ត ក្នុងនោះមាន ៤៥០ លើកជាបេសកកម្មនៅក្រៅមណ្ឌល និង ៥៩១លើកជាបេសកកម្មនៅក្នុងមណ្ឌល។

**គណៈកម្មការជំនាញនៃរដ្ឋសភា៖** តាមការសង្កេតរបស់ខុមហ្វ្រែល ក្នុងចំណោមគណៈកម្មការជំនាញទាំង ១០របស់រដ្ឋសភា មានតែ ៨គណៈកម្មការជំនាញទេ ដែលបានធ្វើសកម្មភាព។ គណៈកម្មការដែលមិនមានសកម្មភាពនោះមាន គណៈកម្មការទី៥ និងទី១០។ គណៈកម្មការជំនាញដែលបានធ្វើសកម្មភាពមានចំនួន ៩៨លើក។ ក្នុងចំណោម គណៈកម្មការដែលបានធ្វើសកម្មភាពមាន ៤គណៈកម្មការដែលមានបេសកកម្មច្រើនជាងគេក្នុងនោះមានគណៈកម្មការជំនាញទី៣ ទី៧ ទី៨ និងទី៩។

សកម្មភាពដែលគណៈកម្មការជំនាញចុះមូលដ្ឋាន ភាគច្រើនក្នុងគោលបំណងចុះសិក្សាស្វែងយល់មានចំនួន ៨៨លើក។ ការចុះសិក្សាស្វែងយល់នេះគឺ ចុះជួបជាមួយប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន ដើម្បីចូលរួមសិក្សាស្វែងយល់ពីបញ្ហានានា ដូចជាការអនុវត្តច្បាប់ និងការឆ្លើយតបដោយមានភាពយឺតយ៉ាវរបស់អាជ្ញាធរជាមួយប្រជាពលរដ្ឋ។

ខុមហ្វ្រែលក៏សង្កេតឃើញថាគណៈកម្មការជំនាញក្នុងឆ្នាំទី១ នៃអាណត្តិទី៦ នេះមានការកោះហៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មកសាកសួរផងដែរ តែទោះជាយ៉ាងណាការហៅសាកសួរនោះមិនបានផ្តោតលើបញ្ហាអយុត្តិធម៌ដែលបានកើតមាននៅក្នុងសង្គមខ្មែរនោះទេ ជាពិសេសប្រជាពលរដ្ឋដែលរងគ្រោះដោយបញ្ហាដីធ្លី ការកាប់ព្រៃឈើ ការប្រើប្រាស់កងកម្លាំងហួសហេតុក្នុងការដេញប្រជាពលរដ្ឋនាំឱ្យមានរងរបួសដោយការអនុវត្តិសាលដីការបស់តុលាការកំពូលជាដើម។ល។

**ការវិភាគសកម្មភាពតំណាងរាស្ត្រ៖** ខុមហ្វ្រែលបានជ្រើសរើសសកម្មភាពរបស់តំណាងរាស្ត្រទាំង១០រូប ដែលមានសកម្មភាពសកម្មជាងគេតាមការសង្កេតក្នុងសម័យប្រជុំរដ្ឋសភា និងការចុះមូលដ្ឋាន។ ជាលទ្ធផលបានបង្ហាញថា តំណាងរាស្ត្រដែលមានតួនាទីជាសមាជិករដ្ឋាភិបាល ឬតួនាទីក្រៅពីស្ថាប័នរដ្ឋសភា បានចុះបេសកកម្មច្រើនជាងតំណាងរាស្ត្រមានតួនាទីក្នុងស្ថាប័នរដ្ឋសភា ក៏ប៉ុន្តែការបញ្ចេញមតិយោបល់ក្នុងសម័យប្រជុំសភា ខុមហ្វ្រែលសង្កេតឃើញថា អ្នកដែលមានមុខតំណែងក្នុងរដ្ឋាភិបាលបានបញ្ចេញមតិតិចតួច ឬមិនមានទាល់តែសោះ។ តំណាងរាស្ត្រដែលមានតួនាទីក្នុងរាជរដ្ឋាភិបាលមានដូចជា សម្តេចក្រឡាហោម **ស ខេង** តំណាងរាស្ត្រមណ្ឌលខេត្តបាត់ដំបង ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ សម្តេចពិជ័យសេនា **ទៀ បាញ់** តំណាងរាស្ត្រមណ្ឌលខេត្តសៀមរាប ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ។ ឯកឧត្តម **កែ គីមយ៉ាន** តំណាងរាស្ត្រមណ្ឌលខេត្តបន្ទាយមានជ័យ ជាឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន។

# សន្និដ្ឋាន

ក្នុងនីតិកាលទី៦ រដ្ឋសភាមានបក្សតែមួយ ស្ថិតក្រោមការដឹកនាំរបស់គណបក្សកាន់អំណាច។ សម្រាប់ការងាររបស់រដ្ឋសភាក្នុងឆ្នាំទី១ នៃនីតិកាលទី៦ ខុមហ្វ្រែលបានសង្កេតឃើញថារាល់សកម្មភាពនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រក្នុងគោលបំណង សំណេះសំណាលជាមួយប្រជាពលរដ្ឋ ពង្រឹងផ្ទៃក្នុងរបស់គណៈបក្ស អមដំណើរថ្នាក់ដឹកនាំ មានចំនួនផុសផុលច្រើន តែសម្រាប់គោលបំណងនៃការចុះជួយអន្តរាគមន៍ដោះស្រាយបញ្ហានានា (ជាពិសេសទំនាស់ដីធ្លី) ជូនប្រជាពលរដ្ឋ មិនឃើញមានតំណាងរាស្ត្រយកចិត្តទុកដាក់នោះទេ។ ដោយឡែក ចំពោះសម័យប្រជុំរដ្ឋសភាក្នុងឆ្នាំទី១ នៃនីតិកាលទី៦ រដ្ឋសភាបានបើកសម័យប្រជុំទាំងសាមញ្ញសាធារណៈ និងវិសាមញ្ញសាធារណៈ ក្នុងសម័យប្រជុំទាំងនោះភាគច្រើនគឺផ្តោតលើការអនុម័តច្បាប់។ អ្វីដែលខុមហ្វ្រែលបានសង្កេតឃើញ ការឡើងបញ្ចេញមតិក្នុងការអនុម័តនូវច្បាប់នានា អ្នកតំណាងរាស្ត្រភាគច្រើនបំផុតក្នុងសម័យប្រជុំទាំងនោះ មិនឃើញមានតំណាងរាស្ត្រណាម្នាក់ជំទាស់ រិះគន់ ឬសួរដេញដោលឡើយ ដោយជំនួសមកវិញមានតែការសសើរ និងគាំទ្រដល់ការដឹកនាំរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះ។ ចំពោះការកោះហៅសមាជិករាជរដ្ឋាភិបាលនៅក្នុងឆ្នាំទី១នេះ មានម្តងគត់គឺ កោះហៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មកសារសួរ។ ការសារសួរនេះ តំណាងរាស្ត្រនៃរដ្ឋសភាមិនបានឱ្យរដ្ឋមន្ត្រីបកស្រាយអំពីភាពអយុត្តិធម៌នៅប្រទេសកម្ពុជាឡើយ តែបែរជាឱ្យរដ្ឋមន្ត្រីជួយបំភ្លឺអំពីការងារដែលសម្រេចបានកន្លងមក និងផែនការដែលត្រូវធ្វើទៅថ្ងៃខាងមុខទៅវិញ។ មួយវិញទៀត ការយកចិត្តទុកដាក់ចំពោះប្រជាពលរដ្ឋ ដូចជាការខ្នះខ្នែងការពារយុត្តិធម៌ ការការពារផលប្រយោជន៍ និងភាពជាតំណាងក្នុងកិច្ចការផ្សេងៗ សំរាប់ប្រជាពលរដ្ឋ ដែលនេះជាការងារចម្បងដែលតំណាងរាស្ត្រត្រូវយកចិត្តទុកដាក់បំផុត តែផ្ទុយទៅវិញអ្វីដែលខុមហ្វ្រែលបានសង្កេតឃើញគឺមិនដែលឃើញមានអ្នកតំណាងរាស្ត្រចេញលិខិតអន្តរាគមន៍ជួយប្រជាពលរដ្ឋឡើយសម្រាប់ឆ្នាំទី១ អាណត្តិទី៦នេះ បើទោះបីជាប្រជាពលរដ្ឋទាំងនោះទាមទារសុំអន្តរាគមន៍រកយុត្តិធម៌ក៏ដោយ។

ជារួម នៅក្នុងឆ្នាំទី១ នៃនីតិកាលទី៦នេះ ខុមហ្វ្រែលបានសង្កេតឃើញថា ប្រសិទ្ធិភាពសភាឯកបក្សមានការធ្លាក់ចុះ បើប្រៀបជាមួយរដ្ឋសភាដែលធ្លាប់មានពហុបក្ស។ ប្រសិទ្ធិភាពនៃការធ្លាក់ចុះនៃរដ្ឋសភាឯកបក្សព្រោះមិនឃើញមានការចេញលិខិតអន្តរាគមន៍របស់តំណាងរាស្ត្រ មិនឃើញមានអ្នកតំណាងរាស្ត្រនិយាយភាពអវិជ្ជមាន ឬអសកម្មក្នុងការដោះស្រាយបញ្ហាជូនពលរដ្ឋរបស់រាជរដ្ឋាភិបាលសោះ មិនឃើញមានតំណាងរាស្ត្រសួរដេញដោលលើការអនុវត្តិច្បាប់ និងសេចក្តីស្នើច្បាប់ឡើយ។

## វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យសម្រាប់ចងក្រងរបាយការណ៍

ដើម្បីធ្វើរបាយការណ៍ប្រចាំឆ្នាំនីមួយៗ ខុមប្រែ្វល បានរៀបចំនូវវិធីសាស្ត្រនៃការចងក្រង និងប្រមូលព័ត៌មានជាប្រចាំ សម្រាប់ចងក្រងទុកធ្វើជារបាយការណ៍ តាមរយៈការប្រើប្រាស់កម្មវិធីកត់ត្រាទិន្នន័យប្រចាំថ្ងៃ។

ខុមប្រែ្វល បានរៀបចំធ្វើរបាយការណ៍ដោយកំណត់ពេលវេលាក្នុងការប្រមូលព័ត៌មានក្នុងឆ្នាំទី១ នីតិកាលទី៦ ចាប់ផ្តើមពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៩។

វិធីសាស្ត្រនៃការប្រមូលព័ត៌មាន ខុមប្រែ្វលបានដាក់មន្ត្រីដើម្បីតាមដាន និងសង្កេតដំណើរការនៃការប្រព្រឹត្តទៅរបស់រដ្ឋសភារួមមាន សម័យប្រជុំរដ្ឋសភា ការឡើងបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ឬការចុះអន្តរាគមន៍របស់អ្នកតំណាងរាស្ត្រ សកម្មភាពរបស់គណៈកម្មការជំនាញជាដើម។

វិធីសាស្ត្រក្នុងការប្រមូលនូវព័ត៌មានដែលពាក់ព័ន្ធសកម្មភាពរបស់តំណាងរាស្ត្រមានដូចជា៖

១. ខុមប្រែ្វល បានបញ្ជូនមន្ត្រី ឬអ្នកស្ម័គ្រចិត្តរបស់ខ្លួនទៅធ្វើការសង្កេតដោយផ្ទាល់នៅក្នុងសម័យប្រជុំនីមួយៗ ក្នុងសម័យប្រជុំរដ្ឋសភា និងការឡើងបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ។

២. ការចុះអន្តរាគមន៍របស់អ្នកតំណាងរាស្ត្រ ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ និងសកម្មភាពគណៈកម្មការជំនាញរបស់រដ្ឋសភា ដូចជាការចុះសិក្សាស្វែងយល់ ការចុះអន្តរាគមន៍ និងការកោះហៅរដ្ឋមន្ត្រីដែលពាក់ព័ន្ធនឹងសកម្មភាពខ្លួនដើម្បីធ្វើការសួរនាំ ខុមប្រែ្វល បានស្រង់ព័ត៌មានតាមរយៈគេហទំព័ររបស់តំណាងរាស្ត្រ និងប្រភពព័ត៌មានផ្សេងៗលើប្រព័ន្ធព័ត៌មានសង្គម។

សកម្មភាពក្នុងចំណុចទី២ គឺជាការកែប្រែនីតិវិធីក្នុងការប្រមូលព័ត៌តាមរយៈការចុះសកម្មភាពដោយផ្ទាល់នៅមូលដ្ឋានជាមួយអ្នកតំណាងរាស្ត្រ ឬការប្រមូលព័ត៌មាននៅការិយាល័យតំណាងរាស្ត្រនៅតាមមណ្ឌលទាំង ២៥រាជធានីខេត្តមកត្រឹមការតាមដាន និងពិនិត្យព័ត៌មានលើប្រព័ន្ធព័ត៌មានសង្គម (ហ្វេសប៊ុកផេក)។ ទោះជាយ៉ាងណាការប្រមូលព័ត៌តាមហ្វេសប៊ុកផេកមានការប្រឈមយ៉ាងខ្លាំង ព្រោះថា ហ្វេសប៊ុកផេករបស់អ្នកតំណាងរាស្ត្រប្រហែលជា ៤០ភាគរយដែលមិនអាចរកឃើញ (ប្រហែលជាអ្នកតំណាងរាស្ត្រមិនប្រើប្រាស់ហ្វេសប៊ុកផេក ឬគណនេយ្យហ្វេសប៊ុកផេក)។

ហេតុនេះ ការប្រមូលរបាយការណ៍សម្រាប់ការចុះបេសកកម្មរបស់តំណាងរាស្ត្រ មានព្រំដែនកំណត់ក្នុងការប្រមូលព័ត៌មាន និងសរសេររបាយការណ៍ ព្រោះព័ត៌មានបង្ហាញត្រឹមអ្វីដែលខុមប្រែ្វលទទួលបាន។

# របាយការណ៍ស្ដីពីការសង្កេតរដ្ឋសភាជាតិ
# ក្នុងឆ្នាំទី១ នីតិកាលទី៦ (២០១៩)

ក្រោយពីគណបក្សសង្គ្រោះជាតិត្រូវបានរំលាយកាលពីដើមឆ្នាំទី៥ នៃនីតិកាលទី៥ យើងឃើញមានគណបក្សចំនួន៤ ដែលមានអាសនៈក្នុងរដ្ឋសភា គឺគណបក្សហ៊្វុនស៊ិនប៉ិច គណបក្សខ្មែរអភិវឌ្ឍសេដ្ឋកិច្ច គណបក្សខ្មែរឈប់ក្រ[1] និងគណបក្សប្រជាជនកម្ពុជា។ ពហុបក្សនៃរដ្ឋសភាក្នុងឆ្នាំទី៥ (២០១៨) នៃនីតិកាលទី៥ ដំណើរការបានត្រឹមតែមួយឆ្នាំប៉ុណ្ណោះ។ ក្រោយពីចប់អាណត្តិទី៥ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៦ (ឆ្នាំ២០១៩-២០២៣) ត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) នៅឆ្នាំ២០១៨ ដែលការបោះឆ្នោតនេះមានគណបក្សនយោបាយចំនួន២០ បានចូលរួមប្រកួតប្រជែងរួមមាន (១). គណបក្សខ្មែររួបរួមជាតិ (២). គណបក្សមាតុភូមិយើង (៣). គណបក្សពន្លឺថ្មី (៤). គណបក្សសញ្ជាតិកម្ពុជា (៥). គណបក្សខ្មែរក្រោក (៦). គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ (៧). គណបក្សប្រជាធិតេយ្យមូលដ្ឋាន (៨). គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ (៩). គណបក្សរស្មីខេមរា (១០). គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ (១១). គណបក្សខ្មែរសាធារណៈរដ្ឋ (១២). គណបក្សខ្មែរឈប់ក្រ (១៣). គណបក្សហ៊្វុនស៊ិនប៉ិច (១៤). គណបក្សខ្មែរអភិវឌ្ឍសេដ្ឋកិច្ច (១៥). គណបក្សយុវជនកម្ពុជា (១៦). គណបក្សធម្មាធិបតេយ្យ (១៧). គណបក្សឆន្ទៈខ្មែរ (១៨). គណបក្សជនជាតិដើមប្រជាធិបតេយ្យ (១៩). គណបក្សខ្មែរតែមួយ និង (២០). គណបក្សប្រជាជនកម្ពុជា។

ជាលទ្ធផលនៃការបោះឆ្នោតនេះ មានតែគណបក្សប្រជាជនកម្ពុជាមួយប៉ុណ្ណោះដែលទទួលបានអាសនៈរដ្ឋសភាទាំង ១២៥ (ស្មើ១០០%នៃអាសនៈ) សម្រាប់នីតិកាលទី៦។

នៅក្នុងនីតិកាលទី៦ រដ្ឋសភាជាតិកម្ពុជាត្រូវបានដឹកនាំដោយឯកបក្សគឺ គណបក្សប្រជាជនកម្ពុជាតែមួយគត់។ គណៈបក្សប្រជាជនកម្ពុជាទទួលបានអំណាចទាំងអស់ក្នុងការអនុម័តច្បាប់នានា ការបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្ត ការដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត រួមទាំងការចុះមូលដ្ឋានផងដែរ។ល។

[1] គណបក្សហ៊្វុនស៊ីនប៉ិចគណបក្ស គណបក្សខ្មែរអភិវឌ្ឍសេដ្ឋកិច្ច គណបក្សខ្មែរឈប់ក្រ ត្រូវបាន គ.ជ.ប បែងចែកអាសនៈរបស់គណបក្សសង្គ្រោះជាតិ ក្រោយពីគណបក្សមួយនេះត្រូវបានតុលាកំពូលរំលាយចោល កាលពីខែ វិច្ឆកា ឆ្នាំ ២០១៨។

## ១. ដំណើរការសម័យប្រជុំនៃរដ្ឋសភា

រដ្ឋសភាបើកសម័យប្រជុំពេញអង្គរបស់ខ្លួនដោយបែងចែកកាលវិភាគជា២ ក្នុងមួយឆ្នាំៗនៃនីតិកាល ហៅថា ប្រជុំសាមញ្ញ ដែលម្តងៗមានរយៈពេល៣ខែ គឺទី១ ចាប់ពីដើមខែកញ្ញា ឆ្នាំ២០១៨ រហូតដល់ដើមខែមករា ឆ្នាំ២០១៩ និងទី២ ពីដើមខែមេសា ឆ្នាំ២០១៩ រហូតដល់ដើមខែកក្កដា ឆ្នាំ២០១៩។ រដ្ឋសភាក៏មានបើកកិច្ចប្រជុំក្រៅកាលវិភាគនេះផងដែរ ក្នុងករណីចាំបាច់ ហៅថា ប្រជុំវិសាមញ្ញ គឺនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩។

ការបើកសម័យដំបូងនៅដើមនីតិកាលទី៦ គឺប្រព្រឹត្តទៅនៅព្រឹកថ្ងៃពុធ ១០រោច ខែស្រាពណ៍ សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។ បន្ទាប់ពីបើកសម័យប្រជុំដំបូងរដ្ឋសភានីតិកាលទី៦ រួចមក រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានបើកសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ព្រឹទ្ធិសមាជិករដ្ឋសភា និងជា ប្រធានរដ្ឋសភាបណ្តោះអាសន្ន ដោយមានវត្តមានបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រនីតិកាលទី៦ ចំនួន១២៥ រូប។ សម័យប្រជុំនេះគឺធ្វើឡើងដើម្បីរៀបចំបង្កើតរដ្ឋសភានៃនីតិកាលថ្មី ដើម្បីសម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងដើម្បីអនុម័តបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នីតិកាលទី៦។ បន្ទាប់មកទៀត **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ព្រឹទ្ធិសមាជិករដ្ឋសភា និងជា ប្រធានរដ្ឋសភាបណ្តោះអាសន្ន បានប្រកាសជូនដំណឹងដល់តំណាងរាស្ត្រទាំងអស់ អញ្ជើញចូលរួមធ្វើពិធីសច្ចាប្រណិធាន នៅព្រះបរមរាជវាំង នារសៀលថ្ងៃពុធ ទី៥ ខែកញ្ញា ឆ្នាំ២០១៨។

សម័យប្រជុំពេញអង្គរដ្ឋសភានីតិកាលនេះ ខុសកាលពីនីតិកាលមុនៗ ដោយក្នុងសម័យប្រជុំដំបូងរបស់រដ្ឋសភានីតិកាលទី៦នេះ មិនមានគណបក្សប្រឆាំង និងអង្គទូតប្រទេសប្រជាធិបតេយ្យទាំងអស់ប្រចាំនៅកម្ពុជាចូលរួមឡើយ។ តែយ៉ាងណាក៏ដោយ សម័យប្រជុំលើកដំបូងនេះ នៅតែដំណើរការទៅដោយរលូនដដែល។

សម័យប្រជុំដំបូងនេះ នឹងសម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងអនុម័តបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានីតិកាលទី៦។ សមាជិករដ្ឋសភាទាំង១២៥រូប សុទ្ធតែសមាជិកមកពីគណបក្សប្រជាជនកម្ពុជា (សភាឯកបក្ស) បានចូលស្បថជាផ្លូវការនៅព្រះបរមរាជវាំង។ ចំណែកថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ រដ្ឋសភាធ្វើការបោះឆ្នោតជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ប្រធាន អនុប្រធានគណៈកម្មការជំនាញ និងផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាលថ្មី។

## ១.១. ចំនួនកិច្ចប្រជុំរដ្ឋសភាពេញអង្គ

នៅឆ្នាំទី១ នៃនីតិកាលទី៦នេះ រដ្ឋសភាបានរៀបចំកិច្ចប្រជុំចំនួន ១១ដង ហើយភាគច្រើនចំណាយពេលមួយព្រឹកក្នុងមួយកិច្ចប្រជុំ ដោយសម្រេចបាននូវរបៀបវារៈចំនួន២៩។ របៀបវារៈទាំងនោះរួមមាន៖

- ការសម្រេចសុពលភាពអាណត្តិរបស់បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ ១២៥រូប នីតិកាលទី ៦ នៃរដ្ឋសភាចំនួន ១
- ការអនុម័តបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាចំនួន ១
- ការបោះឆ្នោតជាកញ្ចប់ ដើម្បីជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ប្រធាន អនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា និងផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាលចំនួន ១
- អានព្រះរាជសាររបស់ព្រះមហាក្សត្រជូនសម័យប្រជុំចំនួន ១
- ក្នុងសម័យប្រជុំលើកទី២ របាយការសង្ខេបអំពីសកម្មភាពរដ្ឋសភានៅចន្លោះសម័យរដ្ឋសភាចំនួន ១
- សេចក្តីព្រៀងច្បាប់ ចំនួន ១៤
- សេចក្តីស្នើវិសោធនកម្មច្បាប់ចំនួន ៣
- ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តចំនួន ៦
- និងការកោះហៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មកបំភ្លឺចំនួន ១។

### ១.១.១ សេចក្តីព្រាងច្បាប់ចំនួន១៤ ដែលរដ្ឋសភាបានពិភាក្សា និងអនុម័តរួមមាន៖

១.) ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៧

២.) ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរបស់ប្រទេសវៀតណាម ស្តីពីការចៀសវាងការយកពន្ធទ្វេដងនិងការការពារការគិបកេងបន្លំ ដែលទាក់ទងនឹងពន្ធលើប្រាក់ចំណូល

៣.) ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩

៤.) ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី

៥.) សេចក្តីព្រាងច្បាប់ ស្តីពីការការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាអោយក្រុមហ៊ុនស្មេថេក ខូអិលធីឌី

៦.) សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាអោយក្រុមហ៊ុនអេសភីអេលភី( ខេមបូឌា)

៧.) សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមអោយព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិកនៃកិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

៨.) សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣

៩.) សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាអោយក្រុមហ៊ុនស្នេចេករីញូវប៊ល

១០.) ការពិភាក្សា និងអនុម័តសេចក្តីព្រៀងច្បាប់ស្តីពី ការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត

១១.) ការពិភាក្សា និងអនុម័តសេចក្តីព្រៀងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដេស ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ

១២.) ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងសហភាពអារ៉ាប់មីរ៉េត ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ

១៣.) ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងព្រះរាជណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋទួកគី ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃការវិនិយោគ

១៤.) ការពិភាក្សា និងអនុម័ត្រសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គការបណ្តាញអន្តរជាតិសម្រាប់ឫស្សី និងផ្តៅ។

**១.១.២ សេចក្តីស្នើវិសោធនកម្មច្បាប់ចំនួន៣ ដែលរដ្ឋសភាបានអនុម័ត និងពិភាក្សារួមមានៈ**

១.) សេក្តីស្នើច្បាប់ស្តីពីវិសោធនកម្មមាត្រា ៤៥ថ្មី (ស្ទួន) នៃច្បាប់ស្តីពីគណបក្សនយោបាយ

២.) សេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

៣.) សេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ។

**១.១.៣ ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តចំនួន៦ ដែលរដ្ឋសភាបានអនុម័ត និងពិភាក្សារួមមានៈ**

១.) ការបោះឆ្នោតជ្រើសតាំងឯកឧត្តម ច័ន្ទ សុផល ជាសមាជិកគណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ

២. ការបោះឆ្នោតជ្រើសតាំងឯកឧត្តម ប្រាជ្ញ ច័ន្ទ ជាសមាជិកគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា និងព្រឹទ្ធសភា

៣.) ការបោះឆ្នោតជ្រើសតាំង លោកជំទាវ លី វួចឡេង ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញសម្រាប់អាណត្តិឆ្នាំ ២០១៩-២០២៨

៤.) ការសម្រេចអំពីសុពលភាពនៃអាណត្តិរបស់ឯកឧត្តម សុខ ផេង ជាតំណាងរាស្ត្រមណ្ឌលខេត្តព្រៃវែង ជំនួសឯកឧត្តម ពៅ សាមុី ដែលបានទទួលមរណៈភាពដោយរោគាពាធ

៥.) ការបោះឆ្នោតជ្រើសតាំងឯកឧត្តម អ៊ិត រ៉ាឌី ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រាប់អាណត្តិថ្មី ជ្រើសដោយរដ្ឋសភានីតិកាលទី០៦ និង

៦.) ការធ្វើការសម្រេចអំពីសុពលភាពនៃអាណត្តិរបស់បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រចំនួន៣៨ រូប ជំនួសតំណាងរាស្ត្រដែលបានលាលែងពីសមាជិករដ្ឋសភានីតិកាលទី៦ រួមមាន៖

| ល.រ | ឈ្មោះតំណាងរាស្ត្រថ្មី | ឈ្មោះតំណាងរាស្ត្រត្រូវផ្លាស់ប្តូរ | មណ្ឌល |
|---|---|---|---|
| ១ | ឯកឧត្តម ភូ ពុយ | ឯកឧត្តម អង្គវង្ស វឌ្ឍនា | បាត់ដំបង |
| ២ | ឯកឧត្តម សៀង ស៊ុតថង | ឯកឧត្តម សក់ សេដ្ឋា | បាត់ដំបង |
| ៣ | ឯកឧត្តម ម៉ា ឈឿន | ឯកឧត្តម ខៀវ កាញារិទ្ធ | កំពង់ចាម |
| ៤ | ឯកឧត្តម អ៊ី សំអុល | ឯកឧត្តម ហង់ជួន ណារ៉ុន | កំពង់ចាម |
| ៥ | លោកជំទាវ ស្រី គឹមឆយ | ឯកឧត្តម វ៉េង សាខុន | កំពង់ចាម |
| ៦ | លោកជំទាវ ខុង ស៊ិនអេង | ឯកឧត្តម ប៉ាន សូរស័ក្តិ | កំពង់ចាម |
| ៧ | លោកជំទាវ កុល ធារិន | ឯកឧត្តម លូ គឹមឈន់ | កំពង់ចាម |
| ៨ | លោកជំទាវ កែ ច័ន្ទមុន | ឯកឧត្តម អ៊ុក រ៉ាប៊ុន | កំពង់ឆ្នាំង |
| ៩ | ឯកឧត្តម ឌួង សុវ៉ាង | ឯកឧត្តម ត្រាំ អ៊ីវតឹក | កំពង់ឆ្នាំង |
| ១០ | ឯកឧត្តម អ៊ូ សំអូន | ឯកឧត្តម ឆាយ ថន | កំពង់ស្ពឺ |
| ១១ | ឯកឧត្តម សំ រិទ្ធី | លោកជំទាវ ខេង សំដារ៉ា | កំពង់ស្ពឺ |
| ១២ | ឯកឧត្តម តុង សេង | ឯកឧត្តម រិន វារៈ | កំពង់ស្ពឺ |
| ១៣ | លោកជំទាវ លឹម ផល្លា | ឯកឧត្តម ថោង ខុន | កំពង់ធំ |
| ១៤ | ឯកឧត្តម ង៉ោ សុវណ្ណ | ឯកឧត្តម លឹម គានហោ | កណ្តាល |
| ១៥ | ឯកឧត្តម អ៊ុក ដាមរី | ឯកឧត្តម ស៊ុន ចាន់ថុល | កណ្តាល |
| ១៦ | ឯកឧត្តម សុះ មុះសិន | ឯកឧត្តម សុខ ចិន្តាសោភា | កណ្តាល |
| ១៧ | ឯកឧត្តម ជីម សុខុន | ឯកឧត្តម វង្សី វិស្សុត | កណ្តាល |
| ១៨ | ឯកឧត្តម ទី សុគន្ធ | ឯកឧត្តម ហ្សាការីយ៉ា អាដាម | កណ្តាល |
| ១៩ | លោកជំទាវ ស៊ុន សាភឿន | ឯកឧត្តម ពេជ្រ ប៊ុនធិន | ក្រចេះ |
| ២០ | ឯកឧត្តម សួន រិនឌី | ឯកឧត្តម អ៊ិត សំហេង | រាជធានីភ្នំពេញ |
| ២១ | ឯកឧត្តម យុត ចាន់ដារ៉ា | ឯកឧត្តម ម៉ម ប៊ុនហេង | រាជធានីភ្នំពេញ |

| | | | |
|---|---|---|---|
| ២២ | ឯកឧត្តម ម៉ក់ វណ្ណស៊ីថា | លោកជំទាវ អ៊ឹង កន្ថាផាវី | រាជធានីភ្នំពេញ |
| ២៣ | លោកជំទាវ ម៉ាណ ណាវី | ឯកឧត្តម អូស្មាន ហាស្សាន់ | រាជធានីភ្នំពេញ |
| ២៤ | ឯកឧត្តម ជាម ប៉េអា | ឯកឧត្តម ព្រុំ សុខា | ព្រៃវែង |
| ២៥ | ឯកឧត្តម ទេព សាម៉ន | ឯកឧត្តម ស សុខា | ព្រៃវែង |
| ២៦ | ឯកឧត្តម ពេជ្រ ជីវ័ន | ឯកឧត្តម ញឹម វណ្ណដា | ព្រៃវែង |
| ២៧ | ឯកឧត្តម ថោង វរលក្ខណ៍ | ឯកឧត្តម ហ៊ី បាវី | ព្រៃវែង |
| ២៨ | ឯកឧត្តម ខៀវ ភារិទ្ធ | ឯកឧត្តម ស្បោង សារ៉ាត | ព្រៃវែង |
| ២៩ | ឯកឧត្តម សារី កោសល្យ | ឯកឧត្តម ស៊ុយ សែម | ពោធិ៍សាត់ |
| ៣០ | ឯកឧត្តម រ៉ូហ្វី អូស្មាន | ឯកឧត្តម កែវ រតនៈ | ពោធិ៍សាត់ |
| ៣១ | ឯកឧត្តម ខូយ សុខា | ឯកឧត្តម ទី នរិន្ទ | ពោធិ៍សាត់ |
| ៣២ | ឯកឧត្តម នេន ម៉ាល័យ | ឯកឧត្តម ប៉ុល សារឿន | ព្រះសីហនុ |
| ៣៣ | ឯកឧត្តម តាក វណ្ណថា | ឯកឧត្តម គឹម ស៊ីថន | ព្រះសីហនុ |
| ៣៤ | ឯកឧត្តម អ៊ិត សុខ | ឯកឧត្តម សុខ ផេង | តាកែវ |
| ៣៥ | ឯកឧត្តម ងួន បឿន | ឯកឧត្តម ចម ប្រសិទ្ធ | កែប |
| ៣៦ | ឯកឧត្តម នៅ សំ | ឯកឧត្តម គន់ គីម | ឧត្តរមានជ័យ |
| ៣៧ | ឯកឧត្តម យិន ប៊ុនណាង | ឯកឧត្តម វង សូត | ត្បូងឃ្មុំ |
| ៣៨ | ឯកឧត្តម សន សារ៉ាណា | ឯកឧត្តម សាយ សំអាល់ | ត្បូងឃ្មុំ |

### ១.១.៤ ការកោះហៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ក្នុងឆ្នាំទី១ នៃនីតិកាលទី៦នេះ រដ្ឋសភាបានកោះហៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មកបំភ្លឺចំនួន១លើក។ រដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌ ឯកឧត្តម អង្គវង្ស វឌ្ឍនា ត្រូវបានគណៈកម្មការជំនាញទី៦ (គណៈកម្មការនីតិកម្ម និងយុត្តិធម៌) កោះហៅមកសាកសួរកាលពីថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៩ អំពីការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៦ ដែលក្រសួងយុត្តិធម៌ត្រូវមានផែនការសកម្មភាព ដូចជាបញ្ហាទាក់ទិនកំណែទម្រង់ច្បាប់ ប្រព័ន្ធយុត្តិធម៌ ការបណ្តុះបណ្តាលធនធានមនុស្ស ផែនការបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌។ ទាក់ទងបញ្ហារដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌ ឯកឧត្តម អង្គវង្ស វឌ្ឍនា បានបង្ហាញពីការផែនការ និងការកសាងមានដូចជា ការកសាងហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន ឱ្យមានសាលាដំបូងរាជធានីខេត្ត សាលាឧទ្ធរណ៍ និងទិសដៅក្នុងការបង្កើតសាលាដំបូងខេត្តកែប ការផ្តល់ជំនួយផ្នែកច្បាប់ និងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

ការផ្តល់សមត្ថភាពជំនាញដល់មន្ត្រីតុលាការ អយ្យការ និងការលើកកម្ពស់វិស័យយុត្តិធម៌ និងច្បាប់ពាក់ព័ន្ធ ដើម្បីជំរុញការដោះស្រាយ និងពង្រឹងយុត្តិធម៌ជូនប្រជាពលរដ្ឋអោយសមស្រប នឹងពេលវេលាតាមនីតិវិធី ដែលបានកំណត់នៅក្នុងច្បាប់។ ផែនការបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាល យុត្តិធម៌ ដើម្បីបំពេញមុខងាររបស់ខ្លួនអោយមានប្រសិទ្ធិភាព។

## ១.២. ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងសម័យប្រជុំ

នៅក្នុងកាលវិភាគនៃការបញ្ចេញមតិក្នុងសម័យប្រជុំ ខុមហ្វ្រែលបានធ្វើការបែងចែកការបញ្ចេញ មតិជា ៣ប្រភេទគឺ អព្យាក្រឹត វិជ្ជមាន និងអវិជ្ជមាន ចំពោះរបៀបវារៈ ឬតួអង្គ/ស្ថាប័នរដ្ឋាភិបាលណាមួយ ដែលអ្នកតំណាងរាស្ត្រលើកមកនិយាយ។ មតិបែបអព្យាក្រឹត គឺសំដៅដល់មតិធម្មតាទៅលើតួអង្គ ឬស្ថាប័ ន។ មតិវិជ្ជមាន គឺផ្តោតលើការលើកសរសើរពីគុណសម្បត្តិរបស់សេចក្តីស្នើច្បាប់ សេចក្តីព្រាងច្បាប់ តួអង្គ ឬរបស់ស្ថាប័នណាមួយ។ រីឯមតិអវិជ្ជមានវិញគឺសំដៅដល់ការនិយាយពីគុណវិបត្តិរបស់តួអង្គ ឬស្ថាប័ន ណាមួយ ឬគុណវិបត្តិនៃសេចក្តីស្នើច្បាប់។

នៅដំណើរការនៃការបើកកិច្ចប្រជុំរបស់រដ្ឋសភាក្នុងឆ្នាំទី១ នៃនីតិកាលទី៦នេះ ខុមហ្វ្រែលសង្កេត ឃើញថា ជាមធ្យមភាគមានអ្នកតំណាងរាស្ត្រចូលរួមសម័យប្រជុំប្រមាណជា១០៥រូប[2] ស្មើនឹងប្រមាណជា ៨៤ភាគរយ នៃចំនួនអ្នកតំណាងរាស្ត្រសរុប១២៥រូប។ ក្នុងសម័យប្រជុំនោះ ខុមហ្វ្រែលឃើញមានអ្នក តំណាងរាស្ត្រចំនួន ១២រូប ស្មើនឹងប្រមាណជា១២ភាគរយ នៃចំនួនអ្នកតំណាងរាស្ត្រចូលរួមសម័យប្រជុំ បានឡើងបញ្ចេញមតិ។

**រូបភាពទី១ សកម្មភាពរបស់តំណាងរាស្ត្រក្នុងសម័យប្រជុំឆ្នាំទី១**

[2] ក្នុងឆ្នាំទី១ នៃអាណត្តិទី៦ រដ្ឋសភាបើសម័យប្រជុំពេញអង្គជាសាធារណៈបាន៩លើកគឺ៖

១. លើកទី១ សម័យប្រជុំធ្វើនៅថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៨ មានអ្នកតំណាងរាស្ត្រចូលរួមសម័យប្រជុំចំនួន ១២៥រូប
២. លើកទី១ សម័យប្រជុំធ្វើនៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៨ មានអ្នកតំណាងរាស្ត្រចូលរួមសម័យប្រជុំចំនួន ៧៧រូប
៣. លើកទី១ សម័យប្រជុំធ្វើនៅថ្ងៃទី ១៥ ខែ វិច្ឆកា ឆ្នាំ ២០១៨ មានអ្នកតំណាងរាស្ត្រចូលរួមសម័យប្រជុំចំនួន ១១៤រូប
៤. លើកទី១ សម័យប្រជុំធ្វើនៅថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៨ មានអ្នកតំណាងរាស្ត្រចូលរួមសម័យប្រជុំចំនួន ១១៥រូប
៥. លើកទី១ សម័យប្រជុំធ្វើនៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៨ មានអ្នកតំណាងរាស្ត្រចូលរួមសម័យប្រជុំចំនួន ១១៥រូប
៦. លើកទី១ សម័យប្រជុំធ្វើនៅថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១៩ មានអ្នកតំណាងរាស្ត្រចូលរួមសម័យប្រជុំចំនួន ១០៨រូប
៧. លើកទី២ សម័យប្រជុំធ្វើនៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៩ មានអ្នកតំណាងរាស្ត្រចូលរួមសម័យប្រជុំចំនួន ១១៣រូប
៨. លើកទី២ សម័យប្រជុំធ្វើនៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៩ មានអ្នកតំណាងរាស្ត្រចូលរួមសម័យប្រជុំចំនួន ១០៨រូប
៩. លើកទី២ សម័យប្រជុំធ្វើនៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩ មានអ្នកតំណាងរាស្ត្រចូលរួមសម័យប្រជុំចំនួន ១១២រូប
១០. លើកទី២ សម័យបើកប្រជុំកោះហៅរដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌មកបំភ្លឺ ធ្វើនៅថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៧ មានអ្នក តំណាងរាស្ត្រចូលរួម ៥៥រូប
១១. សម័យប្រជុំវិសាមញ្ញសាធារណៈត្រូវបានធ្វើនៅថ្ងៃទី១២ ខែសី ហា ឆ្នាំ២០១៩ មានអ្នកតំណាងរាស្រចូលរួមសម័យប្រជុំចំនួន១១១រូប




រូបភាពខាងលើនេះ បង្ហាញថា ក្នុងសម័យប្រជុំឆ្នាំទី១ មានតំណាងរាស្ត្រ១២រូប ដែលបានឡើងបញ្ចេញមតិ និងមានចំនួន ៣៩ដង បើគិតជារយៈពេលមានប្រមាណ ២០៩នាទី។

**ក្រាហ្វិកទី១ ការប្រៀបធៀបមតិបានលើកឡើងរបស់តំណាងរាស្ត្រ**




នៅក្នុងក្រាហ្វិកខាងលើ បើធ្វើការប្រៀបធៀបឆ្នាំទី១ ដូចគ្នានៃអាណត្តិទី៥ និងអាណត្តិទី៦ ខុមហ្វ្រែលសង្កេតឃើញថា ឆ្នាំទី១ នៃអាណត្តិទី៥ មានតំណាងរាស្ត្ររាស្ត្រ ២៣រូប និងរយៈពេលរហូតដល់៦៩៣នាទីឡើងបញ្ចេញមតិច្រើនជាងឆ្នាំទី១ នៃអាណត្តិទី៦។

**ក្រាហ្វិកទី២ ប្រភេទនៃការបញ្ចេញមតិរបស់តំណាងរាស្ត្រក្នុងសម័យប្រជុំ**




តាមការអង្កេតរបស់ខុមហ្វ្រែល ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងការពិភាក្សាលើសេចក្តីព្រាងច្បាប់ សេចក្តីស្នើវិសោធនកម្មច្បាប់ ភាគច្រើនបានផ្តោតលើន័យជាវិជ្ជមាន (សរសើរ គាំទ្រ លើទឹកចិត្តក្នុងការអនុត្តន៍) មានប្រមាណជា ១៧០នាទី ស្មើនឹង ៨១.៣ភាគរយ នៃចំនួនបញ្ចេញមតិសរុប។ ការបញ្ចេញមតិក្នុងន័យអព្យាក្រឹតគឺប្រមាណ ២៣នាទី ស្មើនឹង ១១ភាគរយនៃចំនួនបញ្ចេញមតិសរុប ចំណែកការបញ្ចេញមតិក្នុងន័យបែបអវិជ្ជមានគឺប្រមាណ ១៦នាទីស្មើនឹង ៧.៧ភាគរយនៃចំនួនបញ្ចេញមតិសរុប។ ការបញ្ចេញមតិជាវិជ្ជមានក្នុងសម័យប្រជុំនេះ ខុមហ្វ្រែល បានសង្កេតឃើញមានទស្សនៈលើកឡើងពីផលប្រយោជន៍នៃសេចក្តីព្រាង ឬស្នើច្បាប់ទាំងនោះ ដូចកាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៩ រដ្ឋសភា បានធ្វើការពិភាក្សានិងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត។ ច្បាប់នេះត្រូវបានរដ្ឋសភាគាំទ្រយ៉ាងខ្លាំង ព្រោះវាបានការពារផលប្រយោជន៍ជាតិ និងសម្រាប់ប្រជាពលរដ្ឋខ្មែរផងដែរ។ សម្រាប់មតិអព្យាក្រឹត្យវិញភាគច្រើនផ្តោតសំខាន់លើការសំណូមពរដល់ក្រសួងសាមុី សុំឱ្យអនុវត្តច្បាប់ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយតម្លាភាពមិនលម្អៀង ត្រូវគិតប្រយោជន៍ជាតិជាធំ។ រីឯមតិជាអវិជ្ជមានវិញ តំណាងរាស្ត្របានលើកឡើងភាគច្រើនអំពីចំណុចខ្វះខាត និងភាពទន់ខ្សោយនៃការអនុវត្តិរបស់ក្រសួងសាមុី ដូចកាលពីថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៩ **ឯកឧត្តម ឈាង វុន** បានលើកឡើងចំពោះមុខរដ្ឋមន្ត្រីក្រសួងយុត្តិធម៌គឺ**ឯកឧត្តម អង្សវង្ស វឌ្ឍនា** អំពីភាពអយុត្តិធម៌របស់មន្ត្រីតុលាការខេត្តបាត់ដំប

ង។ ការលើកឡើងនេះ ឯកឧត្តមមិនបានបញ្ចេញឈ្មោះមន្ត្រីតុលាការឡើយ ដោយគ្រាន់តែនិយាយ អំពីការឃុបឃិតរបស់មន្ត្រីតុលាការជាមួយអាជ្ញាធរ ដើម្បីធ្វើបាបប្រជាពលរដ្ឋស្លូតត្រង់តែប៉ុណ្ណោះ ។

**ក្រាហ្វិកទី៣ ការប្រៀបធៀបប្រភេទនៃការបញ្ចេញមតិ**




លទ្ធផលនៃការប្រៀបធៀបប្រភេទនៃការបញ្ចេញមតិរបស់តំណាងរាស្ត្រ បានបង្ហាញថា ឆ្នាំទី១ ដូចគ្នានៃសម័យប្រជុំក្នុងអាណត្តិទី៥ និងទី៦ មានរយៈពេលខុសគ្នា។ ឆ្នាំទី១ នៃអាណត្តិទី៥ មានរយៈពេល ៦៩៣នាទី រីឯអាណត្តិទី៦ មានតែ ២០៩នាទី តិចជាង ៣ដង ហើយនាទីដែលបានបញ្ចេញមតិភាគច្រើនគឺសំដៅលើន័យអព្យាក្រឹត ផ្ទុយពីអាណត្តិទី៦ ការបញ្ចេញមតិភាគច្រើនគឺន័យជាវិជ្ជមាន។

ឆ្នាំទី១ នៃនីតិកាលទី៥ មានគណបក្សនយោបាយ២ មានអាសនៈនៅក្នុងរដ្ឋសភា។ ជាការកត់សម្គាល់ខុមហ្វ្រែលសង្កេតឃើញថា នៅក្នុងឆ្នាំទី១ដូចគ្នានេះ រយៈពេលនៃការបញ្ចេញមតិ សួរដេញដោល និងជជែកបានច្រើនជាងអាណត្តិទី៦។

ក្រាហ្វិកទី៤ រយៈពេលដែលតំណាងរាស្ត្រនីមួយៗបានបញ្ចេញមតិក្នុងសម័យប្រជុំ




ក្រាហ្វិកខាងលើ បានបង្ហាញពីអ្នកតំណាងរាស្ត្រទាំង១២រូប ដែលបានឡើងបញ្ចេញមតិ។ តំណាងរាស្ត្រទាំង ១២រូបនោះមាន ឯកឧត្តម ឈាង វុន បានឡើងធ្វើការបញ្ចេញមតិបានចំនួន ១០ដង ស្មើនឹង ៤៩ នាទី មានរយៈពេលច្រើនជាងតំណាងរាស្ត្រដទៃទៀត។ ក្នុងចំណោមតំណាងរាស្ត្រដែលឡើងបញ្ចេញមតិ មានតំណាងរាស្ត្រជាស្ត្រីតែ ១រូបប៉ុណ្ណោះគឺ លោកជំទាវ ឡោក ខេង បានឡើងធ្វើការបញ្ចេញមតិបានចំនួន ៣ ដង ស្មើនឹង ២១នាទី។

## ២.ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ

នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូកទី៧ មាត្រា៧៧ បានចែងថា តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូលពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ។ តំណាងរាស្ត្រក្រៅពីមានកិច្ចប្រជុំពិភាក្សានៅវិមានរដ្ឋសភា ក៏ត្រូវចំណាយពេលវេលា ចុះទៅតាមមូលដ្ឋានដើម្បីជួប និងដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋ ដែលជាម្ចាស់ឆ្នោតផងដែរ។

ក្នុងន័យនេះ តំណាងរាស្ត្រមានតួនាទីក្នុងការអនុវត្តតាមតួនាទី កាតព្វកិច្ច ដែលច្បាប់ និងបទបញ្ជាផ្ទៃក្នុងបានចែង។ ក្នុងមាត្រា៨៩ មាត្រា៩៦ មាត្រា៩៧ និងមាត្រា៩៨ បង្ហាញពីការផ្តល់អំណាចឱ្យអ្នកតំណាងរាស្ត្រមានសិទ្ធិទម្លាក់រាជរដ្ឋាភិបាល ការហៅសាកសួរ ការដាក់សំណួរទៅរដ្ឋាភិបាល ឬស្តីបន្ទោស។

ការចុះទៅតាមមូលដ្ឋានរបស់តំណាងរាស្ត្រ អង្គការខុមហ្វ្រែលបានកំណត់រាប់ជាចំនួនដង។ ទោះបីជាយ៉ាងណាខុមហ្វ្រែលនៅមានកម្រិតលក្ខខណ្ឌ ឬភាពខ្វះខាតនៃការប្រមូលព័ត៌មានទាក់ទងទៅនឹងសកម្មភាពរបស់តំណាងរាស្ត្រផងដែរ។ លើសពីនេះ ខុមហ្វ្រែល សូមធ្វើការវិភាគលើទិន្នន័យដាក់ក្នុងរបាយការណ៍ត្រឹមព័ត៌មានដែលខុមហ្វ្រែលទទួលបាន ហើយសូមធ្វើការកត់សម្គាល់ថា សកម្មភាពជាក់ស្តែងក៏អាចមានចំនួននៃការចុះតាមមូលដ្ឋានច្រើនជាងទិន្នន័យដែលអង្គការខុមហ្វ្រែលប្រមូលបាននោះផងដែរ។

## ២.១. ចំនួនដង និងចំនួនអ្នកតំណាងរាស្ត្រចុះមូលដ្ឋាន

ក្នុងអាណត្តិទី៦ តំណាងរាស្ត្រទាំងអស់ដែលមានអាសនៈក្នុងរដ្ឋសភាមកពីបក្សតែមួយគឺគណបក្សប្រជាជនកម្ពុជា។ នៅក្នុងឆ្នាំទី១ និតិកាលទី៦ តាមរយៈនៃការសង្កេតរបស់ខុមហ្វ្រែលបានបង្ហាញថា ក្នុងចំណោមតំណាងរាស្ត្រចំនួន ១២៥រូបនៃសមាជិករដ្ឋសភាមានតែ ៥៥រូប[3]ប៉ុណ្ណោះ ដែលបានធ្វើសកម្មភាពនៅមូលដ្ឋាន។ សកម្មភាពដែលតំណាងរាស្ត្របានចុះមូលដ្ឋាននោះ មានចំនួនសរុប ១០៤១លើក[4] ។

**ក្រាហ្វិកទី៥ ចំនួនអ្នកតំណាងរាស្ត្រសរុបបានចុះបេសកកម្មនៅមូលដ្ឋាន**




[3] សកម្មភាពតំណាងរាស្ត្រមិនត្រូវបានរាប់បញ្ចូលចំពោះសកម្មភាពដែលពាក់ព័ន្ធនឹងបេសកកម្មនៅក្រៅប្រទេស, ការប្រជុំពិភាក្សានៅក្នុងក្រុមការងាររបស់ខ្លួន និងការចូលជួបជាមួយគណៈប្រតិភូបរទេស។

[4] មធ្យោបាយនៃការប្រមូលសកម្មភាពតំណាងរាស្ត្រ គឺតាមរយៈហ្វេសបុកផេករបស់អ្នកតំណាងរាស្ត្រ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ

**ក្រាហ្វិកទី៦ ការប្រៀបធៀបបេសកកម្មរបស់តំណាងរាស្ត្រក្នុងឆ្នាំទី១ នៃអាណត្តិទី៥ និងទី៦**




ក្រាហ្វិកខាងលើបានបង្ហាញថា ក្នុងឆ្នាំទី១ ដូចគ្នា ក្នុងអាណត្តិទី៥ មានតំណាងរាស្ត្រសរុប ៩៦រូប ចុះបេសកកម្មតាមមូលដ្ឋានច្រើនជាងតំណាងរាស្ត្រដែលចុះក្នុងអាណត្តិទី៦។ នៅក្នុងក្របខណ្ឌនៃគណបក្សតែមួយក្នុងអាណត្តិទី៥ ឆ្នាំទី១ ការចុះបេសកកម្មនៅមូលដ្ឋានរបស់តំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជាមានចំនួន ៥០រូបស្មើនឹង ៧៤ភាគរយ នៃតំណាងរាស្ត្រមកពីគណបក្សប្រជាជនសរុប ៦៨រូប ដែលមានអាសនៈក្នុងរដ្ឋសភា។ ដោយឡែកអាណត្តិទី៦ ឆ្នាំទី១ តំណាងរាស្ត្រទាំងអស់មកពីគណបក្សប្រជាជនកម្ពុជាមានចំនួន ១២៥រូប តែការចុះបេសកកម្មតាមមូលដ្ឋានមានចំនួនតែ ៥៥រូប ស្មើនឹង ៤៤ ភាគរយ មានន័យថាតំណាងរាស្ត្រក្នុងគណបក្សប្រជាជនកម្ពុជាក្នុងអាណត្តិទី៦ មានអ្នកតំណាងរាស្ត្រចុះបេសកកម្មនៅមូលដ្ឋានមានចំនួនតិចជាងកាលអាណត្តិទី៥។

ផ្អែកលើសកម្មភាពរបស់តំណាងរាស្ត្រក្នុងឆ្នាំទី១ ក្នុងគណបក្សប្រជាជនកម្ពុជាដូចគ្នា ខុមហ្វ្រែល សង្កេតឃើញថា អាណត្តិទី៦ មានចំនួនសកម្មភាពចុះមូលដ្ឋានច្រើនជាងអាណត្តិទី៥ ដោយតំណាងរាស្ត្រ១រូប ជាមធ្យមចុះបានប្រហែល ១៩លើក ទោះបីចំនួនអ្នកតំណាងរាស្ត្រមានចំនួនតិចបានចុះបេសកកម្មក៏ដោយ។

## ២.២ គោលបំណងរបស់តំណាងរាស្ត្រចុះមូលដ្ឋាន

ចំពោះគោលបំណងចុះមូលដ្ឋានរបស់តំណាងរាស្ត្រ ខុមហ្វ្រែលបានបែងចែកយកជា ៥គោលបំណង ដើម្បីសង្កេតទៅលើការចុះតាមមូលដ្ឋានរបស់តំណាងរាស្ត្រ។ គោលបំណងសំខាន់ៗ ទាំង៥នោះ រួមមាន៖ ១.ការសំណេះសំណាល សួរសុខទុក្ខ ចែកអំណោយដល់ប្រជាពលរដ្ឋ ២.ការចុះពង្រឹងផ្ទៃក្នុង

របស់គណៈបក្ស ៣. ការអមដំណើរថ្នាក់ដឹកនាំ ៤.ការចូលរួមវេទិកាសាធារណៈ ៥.ការចុះជួយអន្តរាគមន៍ដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

នៅក្នុងនីតិកាលទី៦ តំណាងរាស្ត្រ ៥៥រូបនៃ ១២៥រូប បានចុះមូលដ្ឋានចំនួន១០៤១លើក ។រាល់សកម្មភាពតំណាងរាស្ត្រដែលបានចុះមូលដ្ឋាន ខុមព្រែល បានចំណាត់ថ្នាក់នៅក្នុងគោលបំណងទាំង៥ ដូចបានរៀបរាប់ខាងលើ។

**ក្រាហ្វិចទី៧ ចំនួន និងភាគរយអ្នកតំណាងរាស្ត្រចុះតាមមូលដ្ឋាន**




តាមក្រាហ្វិចខាងលើបង្ហាញថា ចំនួនភាគរយនៃអ្នកតំណាងរាស្ត្រនៅក្នុងនីតិកាលទី៦ ដែលបានចុះទៅតាមមូលដ្ឋានភាគច្រើនផ្តោតសំខាន់ទៅលើការសំណេះសំណាល សួរសុខទុក្ខ ចែកអំណោយដល់ប្រជាពលរដ្ឋចំនួន ៧០៩លើក ស្មើនឹង៦៨.១ភាគរយ។ សកម្មភាពចំនួន ១៩០លើក ស្មើនឹង ១៨.៣ភាគរយគឺជាការចុះអមដំណើរថ្នាក់ដឹកនាំ។ សកម្មភាពចំនួន ១៣៤លើក ស្មើនឹង១២.៩ភាគរយគឺ ជាការចុះពង្រឹងផ្ទៃក្នុងរបស់គណៈបក្ស រីឯការចុះជួយអន្តរាគមន៍ដោះស្រាយបញ្ហានានា ជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋានមានចំនួន ៨លើកស្មើនឹង ០.៨ភាគរយ ចំណែកឯការចូលរួមនៅក្នុងវេទិកាសាធារណៈរបស់តំណាងរាស្ត្រ តាមការសង្កេត ខុមព្រែល មិនបានទទួលព័ត៌មានទាំងនោះទេ[5]។

[5] រាល់ព័ត៌អំពីសកម្មភាពរបស់អ្នកតំណាងរាស្ត្រ ត្រូវបានប្រមូលតាមរយៈហ្វេសបុក និងផេកផ្ទាល់ខ្លួន។

**ក្រាហ្វិកទី៨ ការប្រៀបធៀបប្រភេទនៃការចុះបេសកកម្ម**




ក្រាហ្វិកខាងលើ គឺជាការប្រៀបធៀបគោលបំណងនៃការចុះបេសកកម្មរបស់តំណាងរាស្ត្រក្នុងឆ្នាំទី១ នៃអាណត្តិទី៥ និងទី៦។ គោលបំណងនៃការចុះបេសកកម្មរបស់តំណាងរាស្ត្រ ក្នុងអាណត្តិទី៦ ខុមហ្វ្រែល មើលឃើញថា ការចុះទៅសំណេះសំណាល សួរសុខទុក្ខ ចែកអំណោយ ការចុះពង្រឹងផ្ទៃក្នុងគណបក្ស និង ការចុះអន្តរាគមន៍ដល់ប្រជាបលរដ្ឋ មានភាគរយកើនឡើងជាងឆ្នាំទី១ នៃអាណត្តិទី៥។ ខុមហ្វ្រែល បាន សង្កេតឃើញផងដែរថា ការចូលរួមវេទិកាសាធារណៈផ្សេងៗមិនមាននោះទេ។

**២.២.១. ការសំណេះសំណាល**

នៅក្នុងឆ្នាំទី១ នីតិកាលទី៦នេះ សកម្មភាពដែលអ្នកតំណាងរាស្ត្របានចុះតាមមូលដ្ឋានក្នុងគោល បំណងបែបសំណេះសំណាល សួរសុខទុក្ខ ចែកអំណាច និងសម្ពោធសមិទ្ធផលនានាជូនប្រជាពលរដ្ឋមាន ចំនួន ៧០៩លើក ស្មើនឹង៦៨.១ភាគរយនៃចំនួនសរុប។ នៅក្នុងចំណុចសំណេះសំណាលនេះ ខុមហ្វ្រែល បានសង្កេតឃើញថា អ្នកតំណាងរាស្ត្របានធ្វើការសម្តែងនូវការកោតសរសើរ និងថ្លែងអំណរគុណយ៉ាង ជ្រាលជ្រៅចំពោះកិច្ចខិតខំប្រឹងប្រែងយកចិត្តទុកដាក់ពីសំណាក់អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ក្នុងការ បំពេញការងារបម្រើប្រជាពលរដ្ឋ និងអភិវឌ្ឍន៍មូលដ្ឋានឲ្យមានសុខសុវត្ថិភាព និងការរីកចម្រើននាពេលប ច្ចុប្បន្ន។ អ្នកតំណាងរាស្ត្រភាគច្រើនគឺធ្វើការចុះជួបជាមួយប្រជាពលរដ្ឋមូលដ្ឋាន ជួបជាមួយកម្មករ ហើយ ផ្តោតទៅលើបញ្ហាប្រទេសជាតិ ដូចជា សន្តិសុខ និងភាពរីករាយរបស់ប្រជាជនខ្មែរ។ មតិនៃការ សំណេះសំណាល និងប្រាប់ទៅប្រជាពលរដ្ឋពីបញ្ហាប្រទេសជាតិដែលស្ថិតក្រោមការដឹកនាំរបស់គណបក្ស ប្រជាជនកម្ពុជាគឺមានសុខសន្តិភាព សិទ្ធិសេរីភាពពេញលេញ មានការអភិវឌ្ឍ ហើយប្រមូលផ្តុំដោយអ្នកវិនិ

យោគពីបរទេស មិនដូចការចោទប្រកាន់របស់គណបក្ស ឬក្រុមប្រឆាំងនោះទេ។ ជាក់ស្តែងកាលពីថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៩[6] **ឯកឧត្តម ច័ន្ទ សុផល** តំណាងរាស្ត្រមណ្ឌលបាត់ដំបង បានអញ្ជើញចុះសួរសុខទុក្ខប្រជាពលរដ្ឋជួបការលំបាកចំនួន ៥គ្រួសារ និងបុណ្យសពចំនួន ១គ្រួសារ ស្ថិតក្នុងក្រុមទី៦ ភូមិអង់ សង្កាត់អូរចារ ក្រុង-ខេត្តបាត់ដំបង ដោយក្នុងមួយគ្រួសារៗទទួលបាន អង្ករ ទឹកស៊ីអ៊ីវ ទឹកត្រី ត្រីខ មី និង ថវិកាមួយចំនួន។

## ២.២.២.ការចុះពង្រឹងផ្ទៃក្នុងរបស់គណៈបក្ស

ក្រោយការរំលាយគណបក្សប្រឆាំងកាលពីខែវិច្ឆិកា ឆ្នាំ២០១៧ គណបក្សកាន់អំណាចបានចាប់ផ្តើមលើកទឹកចិត្តដល់ក្រុមការងារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរបស់ខ្លួន ឱ្យប្រឹងប្រែងបន្តអនុវត្តសកម្មភាពការងារ និងធ្វើការបញ្ចុះបញ្ចូលដល់សមាជិកគណបក្សសង្គ្រោះជាតិ ព្រមទាំងប្រកាសបើកផ្លូវអោយក្រុមសមាជិកគណបក្សប្រឆាំងចូលមកបម្រើកិច្ចការជាមួយគណបក្សប្រជាជនកម្ពុជា ដោយធានារក្សាមុខតំណែង និងទទួលយកគ្រប់ពេលវេលា ដើម្បីជួយអភិវឌ្ឍន៍សង្គមជាតិទាំងមូលផងដែរ។ សរុបសកម្មភាពនៃការចុះពង្រឹងផ្ទៃក្នុងរបស់គណបក្សក្នុងឆ្នាំទី១ នៃនីតិកាលទី៦ មានចំនួន ១៣៤លើក ស្មើនឹង ១២.៩ភាគរយ។

តំណាងរាស្ត្រដែលបានចុះពង្រឹងផ្ទៃក្នុងគណៈបក្សរបស់គណបក្សប្រជាជនកម្ពុជាដែលបានចុះតាមមូលដ្ឋាន ភាគច្រើនបានប្រកាសដំឡើងតំណែងក្រុមប្រឹក្សាឃុំសង្កាត់ និងថ្លែងអំណរអរគុណទៅដល់សមាជិកដែលបានចូលរួមដោះស្រាយ និងខិតខំតស៊ូជាមួយគណបក្សប្រជាជកម្ពុជាកន្លងមក។ នៅក្នុងអំឡុងបំពេញបេសកកម្មអ្នកតំណាងរាស្ត្រទាំងនោះតែងតែរំលឹកពីទិវាជ័យជំនះថ្ងៃ៧ មករា របស់គណបក្សប្រជាជនកម្ពុជា ផ្សព្វផ្សាយទៅដល់ប្រជាជន និងសមាជិកបក្សពីការតស៊ូរបស់មេដឹកនាំរដ្ឋពីសម័យបនប្រល័យពូជសាសន៍ និងរហូតមកដល់បច្ចុប្បន្នទើបធ្វើឲ្យប្រទេសមានសុខសន្តិភាព។ ករណីនេះ ដូចជាកាលពី ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៨[7] ឯកឧត្តម **ជា វ៉ាន់ដេត** តំណាងរាស្ត្រមណ្ឌលខេត្តតាកែវ បានចុះជួបសំណេះសំណាលជាមួយគណបក្សឃុំ និងសាខាបក្សភូមិ ចំនួន ៤ឃុំ គឺ៖ ឃុំលំពង់ ឃុំត្នោត ឃុំចំបក់ និងឃុំកណ្តឹង ដើម្បី៖ទី១- ថ្លែងអំណរគុណដល់គណបក្សឃុំ និងសាខាបក្សភូមិ ចំពោះជោគជ័យនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ទី២- បូកសរុបលទ្ធផលប្រលងប្រណាំងនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ ទី៣- ផ្សព្វផ្សាយពីការវិវឌ្ឍសភាពការណ៍នយោបាយថ្មីនៅក្នុងប្រទេស និងទី៤- ណែនាំដល់គណបក្សឃុំ និងសាខាបក្សភូមិ ត្រូវបន្តអនុវត្តភារកិច្ចចំពោះមុខរហូតដល់ការបោះឆ្នោតនៅឆ្នាំ២០២២ មានជាអាទិ៍៖ ការពង្រឹងសេវាសាធារណៈនៅមូលដ្ឋាន ការលើកកម្ពស់

[6] គណនីហ្វេសប៊ុក "មន្តស្នេហ៍ បាត់ដំបង"

[7] គណនីហ្វេសប៊ុក "Chea Vandeth - ជា វ៉ាន់ដេត"

ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈការចុះជួយអភិវឌ្ឍន៍ជាក់ស្តែងនៅក្នុងមូលដ្ឋាន។ ចំណុចសំខាន់ជាចម្បងគឺការក្សាសាមគ្គីភាព និងឯកភាពផ្ទៃក្នុង មិនថាសមាជិកចាស់ ឬថ្មីឡើយ។

### ២.២.៣. អមដំណើរថ្នាក់ដឹកនាំ

ខុមហ្វ្រែល បានសង្កេតឃើញថាមានអ្នកតំណាងរាស្ត្រដែលបានចូលរួមអមដំណើរព្រះមហាក្សត្រ ថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់ក្នុងប្រទេសមានចំនួន ១៩០លើក ស្មើនឹង ១៨.៣ភាគរយ។ ការអមដំណើរដែលខុមហ្វ្រែលសង្កេតឃើញគឺការចុះទៅអមព្រះរាជដំណើរព្រះមហាក្សត្រក្នុងប្រទេស និងក្រៅប្រទេស។ ក្រៅពីអមដំណើរព្រះមហាក្សត្រ ក៏ឃើញមានការចូលរួមអមដំណើរថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ក្នុងកិច្ចប្រជុំថ្នាក់ជាតិពីបញ្ហានយោបាយ សេដ្ឋកិច្ច វប្បធម៌ ការទូត និងការថ្លែងសុន្ទរកថា រួមទាំងការចុះជួបប្រជាពលរដ្ឋផងដែរ។

### ២.២.៤. ការចុះជួយអន្តរាគមន៍

ខុមហ្វ្រែល បានសង្កេត និងបានប្រមូលព័ត៌មានពីការចុះអន្តរាគមន៍របស់អ្នកតំណាងរាស្ត្រផងដែរ ដែលមានចំនួន ៨លើក ស្មើនឹង ០.៨ភាគរយ។ ការចុះអន្តរាគមន៍នេះ ខុមហ្វ្រែល បានសង្កេតឃើញអ្នកតំណាងរាស្ត្រចុះជួយទៅដល់មូលដ្ឋាន និងតំបន់ដែលពាក់ព័ន្ធជួបបញ្ហា ដូចជាបញ្ហាទាក់ទងបរិស្ថាន កសិកម្ម។ ករណីដែលអ្នកតំណាងរាស្ត្រចុះជួយអន្តរាគមន៍នេះ មានដូចខាងក្រោម៖

- ខេត្តរតនៈគីរី មាន ២ករណី
  - ករណីទី១ បានកើតឡើង នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៨[8] បានចុះជួយអន្តរាគមន៍ទាក់ទងនឹងបញ្ហាការបំពុលបរិស្ថាន (កន្លែងគំនរសំរាម)ស្ថិតនៅភូមិបីសង្កាត់កាចាញ ភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក និងប្រជាពលរដ្ឋភូមិ ជ្រៃ សង្កាត់យក្ខឡោម ក្រុងបានលុង។ ក្រុមហ៊ុន គឹម ជ្រា ត្រូវបានអាជ្ញាធរខេត្តសម្រេចចិត្តចេញលិខិតដោយបញ្ឈប់ក្រុមហ៊ុនប្រមូលសំរាមនេះនៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១៨។ បេសកកម្មនេះ ដឹកនាំដោយ **ឯកឧត្តម ប៊ូ ឡាំ តំណាងរាស្ត្រមណ្ឌលរតនគិរី** ពេលចុះមកដល់ទីតាំងទាំងពីរនេះ ឃើញថាពិតជាធ្វើអោយប៉ះពាល់សុខភាពសាធារណៈពិតប្រាកដមែន ឯកឧត្តមបានស្នើដល់អាជ្ញាធរពាក់ព័ន្ធមានវិធានការផ្លូវច្បាប់ចំពោះបុគ្គល ជា គួង ជាបន្ទាន់។ **ឯកឧត្តម** បានសង្កត់ធ្ងន់ថា "ខ្ញុំមិនបណ្តែតបណ្តោយឲ្យប្រជាពលរដ្ឋខ្ញុំរងទុក្ខលំបាកវេទនាទ្រាំរស់ក្នុងបរិយាកាសក្លិនស្អុយអសោចពីគំនរសំរាម និងក្លិនស្អុយអសោចពីកន្លែងសត្វឃាតដ្ឋានគ្មានអនាម័យបែបនេះនោះឡើយ ប្រាក់ខែតំណាងរាស្ត្របានមកពីរាស្ត្រដូចនេះខ្ញុំនឹងធ្វើអ្វីៗគ្រប់បែបយ៉ាងដើម្បីសេចក្តីសុខរបស់ប្រជាពលរដ្ឋខ្ញុំ"។ ក្នុងនាមតំណាងរាស្ត្រមណ្ឌល

[8] គណនីហ្វេសបុក "ឯកឧត្តម ប៊ូ ឡាំ តំណាងរាស្ត្រមណ្ឌលរតនគិរី"

រតនគិរីជាពិសេសតំណាងឲ្យប្រជាពលរដ្ឋទាំងបីភូមិខាងលើបានសំណូមពរដល់សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែននាយករដ្ឋមន្ត្រីនៃព្រះរាជណាចក្រកម្ពុជាចាត់វិធានការចំពោះបុគ្គល **ជា គួង** ឲ្យប្រមូលសំរាមចេញឲ្យអស់ពីមូលដ្ឋានរបស់ប្រជាពលរដ្ឋខាងលើ បើទោះបីជាបុគ្គល ជា គួង អស់សិទ្ធិក្នុងការប្រមូលសំរាមក៏ដោយក៏មិនអោយបុគ្គលនេះរួចខ្លួនពីការទទួលខុសត្រូវក្នុងការបំពុលបរិស្ថាននេះដែរ និងសូមឱ្យបុគ្គល ជា គួង អនុវត្តឲ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសបរិស្ថាន។

- ករណីទី២ នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៩ **ឯកឧត្ត ប៊ូ ឡាំ** អ្នកតំណាងរាស្ត្រមណ្ឌលរតនគិរី អមតំណើរដោយឯកឧត្តម យឹម ផែន អភិបាលរងខេត្ត លោក សយ សូណា ប្រធានមន្ទីរកសិកម្មរុក្ខាប្រម៉ាញ់និងនេសាទបាននាំយកពូជស្រូវដែលជាអំណោយរបស់រាជរដ្ឋាភិបាល តាមរយៈមន្ទីរកសិកម្មរុក្ខាប្រម៉ាញ់និងនេសាទខេត្តផ្តល់ជូនប្រជាពលរដ្ឋចំនួន៤៩គ្រួសារស្ថិតនៅភូមិទៀមលើ និងភូមិឡឺម ឃុំកាចូន ស្រុកវើនសៃ។

- ខេត្តកំពង់ស្ពឺ មាន១ករណីបានកើតឡើងនៅថ្ងៃទី០៤ ខែមិនា ឆ្នាំ២០១៩[9] តំណាងរាស្ត្រឯកឧត្តម **ហ៊ុន ម៉ានី** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ស្ពឺ បានចុះជួយអន្តរាមគន៍តាមពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋចំនួន ៧ឃុំ នៅក្នុងស្រុកភ្នំស្រួច អំពីផលប៉ះពាល់ដែលបណ្តាលមកពីអាជីវកម្មរ៉ែខ្សាច់ និងថ្ម។ តំណាងរាស្ត្រ និងអាជ្ញាធរខេត្ត ស្រុក មន្ទីរ អង្គភាពជុំវិញខេត្ត និងតំណាងក្រុមហ៊ុនបានពិភាក្សារកដំណោះស្រាយ និងឈានទៅដល់ការអនុវត្តន៍ជាក់ស្តែងលើចំណុចដែលបានឯកភាពមួយចំនួន ដែលក្នុងនោះរួមមាន៖ (១).សកម្មភាពនៃការកិន និងការបំផ្ទុះ មិនត្រូវធ្វើហួសពីម៉ោង ៦ព្រឹកដល់ម៉ោង ៦ល្ងាច (២).ការស្រោចទឹកថ្នល់ជាប្រចាំ ដើម្បីបញ្ចៀសផលប៉ះពាល់ដល់ជីវភាព និងសុខភាពប្រជាពលរដ្ឋរស់នៅតាមដងផ្លូវ (៣).ការដឹកជញ្ជូនត្រូវរក្សានូវគម្លាតយ៉ាងតិច ១៥០ម៉ែត្រ ពីរថយន្តមួយទៅរថយន្តមួយ និងដោយរក្សាល្បឿនយឺតបំផុតនៅក្នុងទីប្រជុំជន (៤).ក្រុមហ៊ុនត្រូវរួមគ្នាចេញបដិភាគជួសជុលផ្លូវដែលរងការខូចខាតដោយសារការដឹកជញ្ជូនរបស់ខ្លួនមិនត្រូវធ្វើឱ្យប៉ះពាល់ដល់សហគមន៍ ជីវភាព និងសុខុមាលភាពប្រជាពលរដ្ឋឡើយ។
- ខេត្តប៉ៃលិន នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨[10] មានចំនួន ១ករណីដែលបានកើតឡើង។ **លោកជំទាវ បាន ស្រីមុំ** តំណាងរាស្ត្រមណ្ឌលខេត្តប៉ៃលិន និងអភិបាលខេត្តប៉ៃលិន និងមន្ត្រីបរិស្ថានខេត្តបានដឹកនាំក្រុមការងារចុះជួយធ្វើអន្តរាគមន៍លើក្រុមហ៊ុនកសិដ្ឋានចិញ្ចឹមជ្រូក ដើម្បីដោះស្រាយផលប៉ះពាល់ប្រជាពលរដ្ឋ អំពីបញ្ហាបច្ចេកទេសចិញ្ចឹមជ្រូកដែលនាំឱ្យជះក្លិនមិនល្អដល់សាធារណៈជន ហើយបានថ្លែងអំណរគុណចំពោះ ឧកញ៉ា ជា គា នាយក

[9] គណនីហ្វេសបុក “Hun Many”

[10] ហ្វេសបុកផេក “Ban Sreymom Page”

ក្រុមហ៊ុនកសិដ្ឋានចិញ្ចឹមជ្រូក រួមទាំង មន្ទីរបរិស្ថានខេត្ត ដែលបានចូលរួមដោះស្រាយកែសម្រួលបច្ចេកទេស ផលប៉ះពាល់ទាំងឡាយជូនពុកម៉ែបងប្អូនប្រជាពលរដ្ឋ ដែលមានលំនៅដ្ឋាន ស្ថិតក្នុងភូមិអូរសួស្តី ខេត្តប៉ៃលិនដោយស្មារតីទទួលខុសត្រូវ សប្បាយរីករាយរួមគ្នា ។

## ២.៣.មណ្ឌលរាជធានី ខេត្ត ដែលតំណាងរាស្ត្របានចុះបេសកកម្ម

តំណាងរាស្ត្រក្នុងរដ្ឋសភាជាតំណាងរាស្ត្រប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ(រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៧៧)។ ទោះជាយ៉ាងណាតំណាងរាស្ត្រក៏មានមណ្ឌលរបស់ខ្លួនដែលត្រូវទទួលខុសត្រូវដែរ តែជាក់ស្តែងការចុះបេសកកម្មរបស់តំណាងរាស្ត្រ ខ្លះមាននៅក្នុងមណ្ឌលរបស់ខ្លួន តែពេលខ្លះបានចុះទៅក្រៅមណ្ឌល។

**ក្រាហ្វិកទី៩ បេសកកម្មតំណាងរាស្ត្រតាមមណ្ឌល**




តំណាងរាស្ត្រឯកបក្សរបស់គណបក្សប្រជាជនកម្ពុជាចំនួន ៥៥រូប បានចុះបេសកកម្មទៅមូលដ្ឋានសរុបមានចំនួន ១០៤១លើក ក្នុងនោះតំណាងរាស្ត្រ ដែលបានចុះមូលដ្ឋាននៅក្នុងមណ្ឌលរបស់ខ្លួនមានចំនួន ៥៩១លើក។ ចំណែកការចុះមូលដ្ឋានរបស់តំណាងរាស្ត្រក្រៅមណ្ឌលរបស់ខ្លួនមានចំនួន៤៥០លើក[11]។

[11] ការប្រមូលសកម្មភាពរបស់តំណាងរាស្ត្រ ខុមហ្វ្រែលយកតែតំណាងរាស្ត្រដែលជាប់ឆ្នោតនៅក្នុងរដ្ឋសភាប៉ុណ្ណោះ

## ក្រាហ្វិចទី១០ ចំនួនខេត្តដែលអ្នកតំណាងរាស្ត្រចុះមូលដ្ឋាន




តាមការបង្ហាញរបស់ក្រាហ្វិចខាងលើ ចំពោះសកម្មភាពអ្នកតំណាងរាស្ត្រដែលបានចុះមូលដ្ឋានក្នុងមណ្ឌល និងក្រៅមណ្ឌលក្នុងនោះមានរាជធានី-ខេត្តចំនួនពីរដែលបានចុះធ្វើសកម្មភាពច្រើនជាងគេគឺ រាជធានីភ្នំពេញ និងខេត្តបន្ទាយមានជ័យ។

## ៣. គណៈកម្មការជំនាញនៃរដ្ឋសភា

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ មាត្រា៩៨(ថ្មី) បានផ្តល់អំណាចយ៉ាងធំធេងសម្រាប់ស្ថាប័ននីតិបញ្ញត្តិ រហូតដល់ស្ថាប័នមួយនេះមានសិទ្ធិអំណាច ទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង ប្រសិនបើរកឃើញកំហុសក្នុងការអនុវត្តិមិនបានត្រឹមត្រូវ មិនតែប៉ុណ្ណោះ មាត្រា៩៦ និងមាត្រា៩៧ បានផ្តល់អំណាចដល់គណៈកម្មការជំនាញរបស់រដ្ឋសភា អាចអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន ហើយតំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល ហើយសំណួរនេះត្រូវសរសេរជាលាយលក្ខណ៍អក្សរប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា។

នៅក្នុងឆ្នាំទី១ (ឆ្នាំ២០១៩)នេះ ការសង្កេតរបស់ខុមហ្វ្រែលរកឃើញ[12]ថា គណៈកម្មការជំនាញទាំង១០ នៃរដ្ឋសភាមានតែគណៈកម្មការជំនាញតែ៨[13]ប៉ុណ្ណោះដែលបានធ្វើសកម្មភាព សរុបចំនួន ៩៨ លើក[14]។ សកម្មភាពទាំងនេះមានគោលបំណងភាគច្រើនផ្តោតលើការចុះសួរសុខទុក្ខ ចែកអំណោយ ធ្វើការផ្សព្វផ្សាយ និងធ្វើការសិក្សាស្វែងយល់អំពីតួនាទីមន្ត្រីនៅតាមមូលដ្ឋាន។ល។ ការកោះហៅរដ្ឋមន្ត្រីមកសាកសួរអំពីការងារដែលជាទំនួលខុសត្រូវរបស់ខ្លួន។ ចំណែកសកម្មភាពរបស់គណៈកម្មការជំនាញដែលពាក់ព័ន្ធនឹងការចុះអន្តរាគមន៍ ដើម្បីជួយប្រជាពលរដ្ឋរងគ្រោះដោយសារបញ្ហាផ្សេងៗ ដូចជាការរំលោភយកដីធ្លីពីសំណាក់អ្នកមានអំណាច ឬប្រជាពលរដ្ឋដែលទទួលរងនូវភាពអយុត្តិធម៌ ខុមហ្វ្រែលសង្កេតឃើញថាមិនដែលឃើញគណៈកម្មការជំនាញណាមួយ ចុះធ្វើការសិក្សាស្វែងយល់ សួរនាំ ឬអន្តរាគមន៍ដោះស្រាយជូនប្រជាពលរដ្ឋឡើយ។

[12] រាល់ព័ត៌អំពីសកម្មភាពរបស់គណៈកម្មការជំនាញទាំង១០នៃរដ្ឋសភា ត្រូវបានប្រមូលតាមវេបសាយផ្លូវការរបស់រដ្ឋសភាជាតិ។

[13] គណៈកម្មការទី៥ គឺ គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន និងគណៈកម្មការទី១០ គណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ មិនឃើញមានសកម្មភាពនៅក្នុងឆ្នាំទី១ឡើយ។

[14] សកម្មភាពគណៈកម្មការជំនាញមិនត្រូវបានរាប់បញ្ចូល ចំពោះសកម្មភាពដែលពាក់ព័ន្ធនឹង បេសកម្មនៅក្រៅប្រទេស, ការប្រជុំពិភាក្សានៅក្នុងក្រុមការងាររបស់ខ្លួន និងការចូលជួបជាមួយគណៈប្រតិភូបរទេស។

**ក្រាហ្វិកទី១១ សកម្មភាពរបស់គណៈកម្មការជំនាញ**




តាមការសង្កេតរបស់ខុមហ្វ្រែល គណៈកម្មការជំនាញដែលបានធ្វើសកម្មភាពរួមមាន៖ គណៈកម្មការទី១ មានសកម្មភាព ៦លើក គណៈកម្មការទី២ មានសកម្មភាព ២លើក គណៈកម្មការទី៣ មានសកម្មភាព ១៦លើក គណកម្មការទី៤ មានសកម្មភាព ៨លើក គណៈកម្មការជំនាញទី៦ មានសកម្មភាព ២លើក គណៈកម្មការទី៧ មានសកម្មភាព ២៩លើក គណៈកម្មការទី៨ មានសកម្មភាព២០លើក គណៈកម្មការជំនាញទី៩ មានសកម្មភាព១៥លើក ចំណែកឯគណៈកម្មការជំនាញទី៥ និងទី១០ ខុមហ្វ្រែលពុំឃើញមានសកម្មភាពអ្វីឡើយ។

បេសកកម្មរបស់គណៈកម្មការជំនាញ ត្រូវបានបែងចែកដោយឡែកពីសកម្មភាពរបស់តំណាងរាស្ត្រ។ គណៈកម្មការជំនាញមានភារកិច្ចទទួលបន្ទុកត្រួតពិនិត្យទៅលើស្ថាប័ន ឬក្រសួងដែលពាក់ព័ន្ធ ជាពិសេសគឺការចុះទៅមូលដ្ឋានដើម្បីជួយដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋ នៅពេលអាជ្ញាធរនៅតាមមូលដ្ឋានមិនបានបំពេញតួនាទីអោយបានត្រឹមត្រូវ ឬមានអំពើអយុត្តិធម៌កើតឡើងជាដើម។ គណៈកម្មការជំនាញមានតួនាទីសិក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលបានបញ្ជូនមកពីគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាតាមមុខជំនាញរបស់ខ្លួន និងអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺអំពីបញ្ហាអ្វីមួយដែលទាក់ទង នឹងវិស័យទទួលខុសត្រូវរបស់ខ្លួន។

យោងលើសកម្មភាពជាក់ស្តែង បើទោះបីជារដ្ឋធម្មនុញ្ញបានប្រគល់អំណាចទៅអោយស្ថាប័នមួយនេះយ៉ាងណាក៏ដោយ ក៏ស្ថាប័នរដ្ឋសភានេះមិនបានប្រើអំណាចរបស់ខ្លួនអោយមានប្រសិទ្ធិភាពនៅក្នុងតួ

នាទីជាតំណាងរបស់ប្រជាពលរដ្ឋឱ្យបានពេញលេញដែរ ជាពិសេសពាក់ព័ន្ធនឹងអន្តរាគមន៍ក្នុងការជួយដោះស្រាយ ការសួរនាំ ឬសិក្សាស្វែងយល់អំពីបញ្ហាដែលកើតមានចំពោះប្រជាពលរដ្ឋក្នុងការប្រឈមជាក់ស្តែងលើបញ្ហាដីធ្លីនៅកម្ពុជា បញ្ហាព្រៃឈើ បញ្ហាសន្តិសុខជាតិ ឬការកោះហៅរដ្ឋមន្ត្រីរាជរដ្ឋាភិបាលមកបំភ្លឺលើវិស័យយុត្តធម៌ ឬសេដ្ឋកិច្ចនោះដែរ។

## ៣.១ គោលបំណងនៃការចុះបេសកកម្មរបស់គណៈកម្មការជំនាញ

ការចុះទៅមូលដ្ឋានគឺជាផ្នែកសំខាន់មួយនៅក្នុងចំណោមភារកិច្ចសំខាន់ៗផ្សេងទៀត ព្រោះគណៈកម្មការជំនាញមានសមាសភាពជាអ្នកតំណាងរាស្ត្រ និងភាពជាតំណាងរបស់ពលរដ្ឋ ដែលមានតួនាទីក្នុងការឃ្លាំមើលការអនុវត្តច្បាប់របស់រាជរដ្ឋាភិបាល និងការងារនីតិកម្មជាដើម។

គោលបំណងនៃការចុះបេសកម្មរបស់គណៈកម្មការជំនាញ មានសកម្មភាពដូចជា ការចុះបេសសកម្មដោយជួបអាជ្ញាធរមូលដ្ឋានតាមមន្ទីរ ឬតាមក្រសួង ស្ថាប័ននានា ដើម្បីធ្វើការសិក្សាស្វែងយល់ពីតួនាទីរបស់ខ្លួន និងការចុះសួរសុខទុក្ខប្រជាពលរដ្ឋ។

**ក្រាហ្វិចទី១២ គោលបំណងនៃសកម្មភាពរបស់គណៈកម្មការជំនាញ**



តាមក្រាហ្វិចខាងលើបង្ហាញថា គោលបំណងរបស់គណៈកម្មការជំនាញភាគច្រើនផ្តោតទៅលើការចុះសិក្សាស្វែងយល់ពីតួនាទីរបស់ខ្លួន[15]មានចំនួន ៨៨លើកស្មើនឹង ៨៩.៨ភាគរយ ការចុះជួបពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋានមានចំនួន ៨លើកស្មើនឹង ៨.២ភាគរយ ការចុះសួរសុខទុក្ខមានចំនួន ២លើកស្មើនឹង ២ភាគរយ ចំណែកឯសកម្មភាពដែលពាក់ព័ន្ធនឹងការចុះអន្តរាគមន៍ ខុមហ្វ្រែល មិនទទួលបានព័ត៌មានទាំងនេះឡើយ។

ចំណែកឯគោលបំណងដើម្បីចុះអន្តរាគមន៍ ទទួលពាក្យបណ្តឹង ឬសួរនាំប្រជាពលរដ្ឋដែលទទួលរងនូវភាពអយុត្តិធម៌ក្នុងសង្គម ដូចជា ការរំលោភយកដីធ្លី ឬការបណ្តេញចេញដោយបង្ខំពីសំណាក់អាជ្ញាធរ ខុមហ្វ្រែល មិនទទួលបានព័ត៌មានទាំងនេះឡើយ។

ខុមហ្វ្រែលបានសង្កេតឃើញថា សកម្មភាពដែលគណៈកម្មការជំនាញកោះហៅរដ្ឋមន្ត្រីមកបំភ្លឺចំពោះមុខរដ្ឋសភាជាតិមានតែមួយលើកប៉ុណ្ណោះ គឺការកោះហៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ការកោះហៅមកបំភ្លឺនេះគឺសាកសួរពីវិស័យការងាររបស់ក្រសួង តែរដ្ឋសភាមិនបានផ្តោតលើការសាកសួរពីភាពអយុត្តិធម៌ដែលកើតមានស្ទើរទូទាំងប្រទេសនោះទេ។

ក្នុងឆ្នាំទី១ នៃអាណត្តិទី៦ ខុមហ្វ្រែលបានសង្កេតឃើញមានសកម្មភាពអយុត្តិធម៌ជាច្រើនបានកើតឡើង ដូចជាការចាប់ខ្លួនសកម្មជនដីធ្លី ការប្រើអាវុធហួសហេតុបណ្តាលឱ្យមានរបួសស្នាមដល់អ្នកតវ៉ាដីធ្លី ការចាប់ និងយាយីលើសកម្មជនអតីតៈគណបក្សប្រឆាំងដែលតុលាការកំពូលបានរំលាយកាលខែវិច្ឆិកា ឆ្នាំ២០១៧ ជាដើម តែមិនបានឃើញគណៈកម្មការជំនាញចុះសិក្សា ពិនិត្យ ឬហៅអ្នកពាក់ព័ន្ធមកសាកសួរនោះទេ។

### ៣.១.១. ការចុះដើម្បីសិក្សាស្វែងយល់អំពីតួនាទីរបស់ខ្លួន

នៅក្នុងឆ្នាំទី១ នៃនីតិកាលទី៦ សកម្មភាពគណៈកម្មការជំនាញបានចុះសិក្សាស្វែងយល់មានចំនួន ៩៥លើក។ នៅក្នុងអំឡុងពេលបំពេញបេសកកម្មគណៈកម្មការជំនាញបានចុះទៅជួបជាមួយប្រជាពលរដ្ឋ និងជួបអាជ្ញាធរនៅតាមមូលដ្ឋានដើម្បីសិក្សាស្វែងយល់ពីបញ្ហានានា ដូចជា ការស្វែងយល់ពីការអនុវត្តច្បាប់ និងការឆ្លើយតបមានភាពយឺតយ៉ាវរបស់អាជ្ញាធរជាមួយពលរដ្ឋ។ សកម្មភាពក្នុងការចុះសិក្សាស្វែងយល់មានដូចជា សិក្សាស្វែងយល់ពីវឌ្ឍនភាពការងារ បញ្ហាប្រឈមរបស់អាជ្ញាធរខេត្ត និងមន្ទីរជំនាញពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់គណៈកម្មការ ដើម្បីបំពេញតួនាទីជាតំណាងរាស្ត្រ ដែលមានភារកិច្ច។ ស្វែងយល់ពីតម្រូវការរបស់ពលរដ្ឋ ក៏ដូចជាតម្រូវការ និងបញ្ហាប្រឈមរបស់អ្នកអនុវត្តច្បាប់ អ្នកផ្តល់សេវាដល់ពលរដ្ឋ ដើម្បីធ្វើយ៉ាងណាអោយពលរដ្ឋទទួលបានសេវានានាពីរដ្ឋកាន់តែងាយស្រួល និងមានប្រសិទ្ធ

[15] ការចុះសិក្សាស្វែងយល់ពីតួនាទីរបស់ខ្លួនមានន័យថា គឺជាការសិក្សាស្វែងយល់ពីភារកិច្ចក្នុងការចុះជួបជាមួយអាជ្ញាធរថ្នាក់ក្រោម ស្វែងយល់ពីសកម្មភាពរបស់ពួកគាត់បានបំពេញតួនាទីជូនប្រជាពលរដ្ឋ និងជួយដោះស្រាយបញ្ហាបានកកម្រិតណា។

ភាព។ បន្ទាប់ពីបានបំពេញបេសកកម្មចុះសិក្សាស្វែងយល់ ខុមហ្វ្រែលបានសង្កេតឃើញមានអាជ្ញាធរមូលដ្ឋានមួយចំនួនបានស្នើអោយគណៈកម្មការជំនាញដែលបានចុះទៅដល់នោះ ជួយដោះស្រាយបញ្ហាដែលកើតឡើង ដូចករណីព្រឹកថ្ងៃចន្ទ ទី៤ ខែមីនា ឆ្នាំ២០១៩[16] គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹងអង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា ដឹកនាំដោយ ឯកឧត្តម ម៉ា សុជាតិវង្ស ជាប្រធានគណៈកម្មការបានចុះបេសកកម្មស្វែងយល់ពីគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ការរីកចម្រើនរបស់ខេត្ត និងយន្តការដោះស្រាយទំនាស់ដីធ្លីរបស់គណៈអភិបាលខេត្តព្រះវិហារ។

### ៣.១.២ គណៈកម្មការជំនាញបានទៅចុះសួរសុខទុក្ខ

សកម្មភាពរបស់គណៈកម្មការជំនាញបានចុះជួបសួរសុខទុក្ខប្រជាពលរដ្ឋ នៅតាមមូលដ្ឋានមានចំនួន ២លើក ។ ខុមហ្វ្រែល សង្កេតឃើញថា ការចុះជួបនេះក្នុងគោលបំណងដើម្បីសំណេះសំណាល និងផ្តាំផ្ញើដល់អាជ្ញាធរឱ្យប្រឹងប្រែងប្រតិបត្តិការថែរក្សានូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការងារវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីលើកកម្ពស់ការងារប្រជាធិបតេយ្យនៅតាមមូលដ្ឋាននានា។

### ៣.១.៣ ការមិនអន្តរាគមន៍ដោះស្រាយរឿងទំនាស់ដីធ្លី

ខុមហ្វ្រែលបានសង្កេតឃើញថា មានប្រជាពលរដ្ឋរងគ្រោះ និងមានបញ្ហាដីធ្លីនៅក្នុងខេត្តមួយចំនួនដូចជាខេត្តព្រះសីហនុ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង និងខេត្តព្រះវិហារជាដើម ត្រូវបានកងកម្លាំងរាជរដ្ឋាភិបាលធ្វើការបណ្តេញចេញដោយបង្ខំ រហូតដល់កន្លែងខ្លះបានប្រើហឹង្សាលើប្រជាពលរដ្ឋ ដោយចោទប្រកាន់ថាបានកាន់កាប់ដីដោយខុសច្បាប់។ ករណីជាក់ស្តែងមានប្រជាពលរដ្ឋជាងមួយរយគ្រួសារដែលមានទំនាស់ដីធ្លីស្ថិតនៅភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ ២០១៩ កងកម្លាំងសមត្ថកិច្ចចម្រុះប្រហែល ៣00នាក់ បានបើកការបាញ់ប្រហារដោយកាំភ្លើងគ្រាប់ពិតឡើងលើមេឃទៅកាន់ក្រុមអ្នកតវ៉ាដីធ្លី។ ការប្រើប្រាស់កម្លាំងនេះ បានបង្ហាញពីការប្រើប្រាស់កងកម្លាំងច្រើនលើសលប់ ដើម្បីអនុវត្តសាលដីការបស់តុលាការកំពូល ដែលបានសម្រេចផ្តល់ដីទំនាស់ជាង ៧0ហិកតា ដែលមានពលរដ្ឋជាច្រើនរយគ្រួសារកំពុងរស់នៅទីនោះ ទៅឱ្យប្រជាពលរដ្ឋចំនួន ៩គ្រួសារផ្សេងទៀត ដែលគេសង្ស័យថាបានឈរឈ្មោះឱ្យឧកញ៉ា ស៊ីវ គង់ទ្រីវ និងប្រពន្ធឈ្មោះ ហុង សួន។

ក្នុងហេតុការណ៍នោះ បណ្តាលអោយកម្មករសំណង់ម្នាក់អាយុ ២៨ឆ្នាំ ឈ្មោះ ពៅ សារ័ត្ន បានរងរបួសដោយគ្រាប់កាំភ្លើងចំស្មាពីផ្នែកខាងក្រោយ និងបៀមគ្រាប់ជាប់នឹងឆ្អឹងខ្នង។ ចំណែកពលរដ្ឋ ៤នាក់ទៀត ត្រូវបានកងកម្លាំងប្រដាប់អាវុធចាប់ខ្លួន ដោយចងស្លាបសេក ហើយយកកាំភ្លើងវាយដុំ និងយកជើង

16 គណនីហ្វេសបុក “H.E. Maut Yousos”

ជាន់ផ្ទប់នឹងដីថែមទៀត ប៉ុន្តែពលរដ្ឋទាំងនោះត្រូវបានដោះលែងវិញ នៅយប់ថ្ងៃកើតហេតុដោយមានកិច្ចសន្យាឈប់តវ៉ា និងបង់លុយម្នាក់ ១០០ (មួយរយ)ដុល្លារ ព្រមទាំងចិញ្ចៀនមួយវង្ស។[17] ករណីមួយទៀតបានកើតឡើងកាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ មានប្រជាពលរដ្ឋជាង ៣០០គ្រួសារបានធ្វើការបិទផ្លូវនៅតាមបណ្តោយផ្លូវជាតិលេខ៤ ស្ថិតនៅឃុំបិទត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដោយសារពួកគាត់មិនសុខចិត្តនឹងសាលដីការបស់តុលាការ ដែលសម្រេចអោយពួកគាត់ចុះចេញពីដីដែលពួកគាត់កំពុងរស់នៅដោយសាលដីការបានបញ្ជាក់ថាប្រជាពលរដ្ឋទាំងនេះ កំពុងរស់នៅដោយខុសច្បាប់លើដីរបស់លោក ជុំ សាវុឌ្ឍ នៅចំណុចភូមិតារាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។[18] និងមានករណីទំនាស់ធ្លីផ្សេងៗទៀត ដែលបានកើតឡើងនៅទូទាំងប្រទេស មិនទាន់ត្រូវបានដោះស្រាយនៅឡើយ។ យោងទៅតាមរបាយការណ៍សង្ខេបរបស់ក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ចេញផ្សាយ ឆ្នាំ២០១៨កន្លងមកនេះបានឲ្យដឹងថាបញ្ហាវិវាទដីធ្លីទូទាំងប្រទេស នៅសល់ជិត ១៥០០ ករណីទៀតមិនត្រូវបានដោះស្រាយចប់នៅឡើយគិតត្រឹមចុងឆ្នាំ២០១៨។[19]

ចំពោះករណីទំនាស់ធ្លីទាំងនេះ តាមការសង្កេតរបស់ខុមហ្វ្រែលបានអោយដឹងថា មិនមានគណៈកម្មការណាមួយជាពិសេសគឺគណៈកម្មការទី១ ដែលជាគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹងអង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងគណៈកម្មការទី៦ ដែលជាគណៈកម្មការនីតិកម្ម និងយុត្តិធម៌ចុះទៅមូលដ្ឋានដែលមានទំនាស់ដីធ្លីធ្វើការសួរនាំ ឬធ្វើការសម្របសម្រួល ឬដោះស្រាយជូនប្រជាពលរដ្ឋនោះឡើយ។ លើសពីហ្នឹងទៀត តាមការសង្កេតសម័យប្រជុំនីមួយៗនៃរដ្ឋសភាជាតិ ខុមហ្វ្រែលមិនដែលឃើញមានអ្នកតំណាងរាស្ត្រក្នុងគណៈកម្មការណាមួយឡើងបញ្ចេញមតិពាក់ព័ន្ធនឹងវិស័យសិទ្ធិមនុស្ស ដែលទទួលរងនូវផលប៉ះពាល់ដោយសារដីធ្លីឡើយ ផ្ទុយទៅវិញអ្នកតំណាងរាស្ត្រដែលបានឡើងបញ្ចេញមតិភាគច្រើនគឺផ្តោតតែលើការសរសើរការដឹកនាំរបស់រាជរដ្ឋាភិបាល និងគាំទ្រច្បាប់ដែលតំណាងរាជរដ្ឋាភិបាលបានស្នើ។

### ៣.១.៤. ការកោះហៅរដ្ឋមន្ត្រីមកបំភ្លឺចំពោះរដ្ឋសភា

នៅក្នុងឆ្នាំទី១ នៃនីតិកាលទី៦ របស់រដ្ឋសភាជាតិដែលដឹកនាំដោយឯកបក្ស តាមការអង្កេតរបស់ខុមហ្វ្រែលបានឃើញថា ក្នុងចំណោមគណៈកម្មការទាំង១០ នៃរដ្ឋសភាមានគណៈកម្មកាជំនាញតែមួយ

---

[17] ថន ថារ៉ូ វិទ្យុអាស៊ីសេរី, ថ្ងៃទី06 ខែ កុម្ភៈ ឆ្នាំ ២០១៩, "ពលរដ្ឋមានទំនាស់ដីធ្លីនៅខេត្តព្រះសីហនុ សុំអោយមានការដោះស្រាយដល់ពួកគាត់" https://www.rfa.org/khmer/news/land/landdispute-sihanoukville-02062019234955.html

[18] ខុន ប៊ុនថុល កាសែតវាយោ, ថ្ងៃទី 18 ខែ មេសា ឆ្នាំ ២០១៩, "ទំនាស់ដីធ្លីផ្ទុះការតវ៉ា មួយករណីទៀត នៅខេត្តព្រះសីហនុ" https://vayofm.com/news/detail/94658-626622282.html

[19] សេង បារាំង កាសែតវាយោ, ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០១៩, "ក្រសួងដែនដីបដិសេធមិនទទួលដោះស្រាយ រឿងដីធ្លីនៅស្រុកនៃខេត្តត្បូងឃ្មុំhttps://vayofm.com/news/detail/96416-818679999.html

ប៉ុណ្ណោះ គឺគណៈកម្មការទី៦ គណៈកម្មការនីតិកម្ម និងយុត្តិធម៌បានធ្វើការកោះហៅរដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌គឺឯកឧត្តម អង្គ វង្សវឌ្ឍនា មកបំភ្លឺពីវិស័យការងាររបស់ខ្លួន កាលពីព្រឹកថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៩ នៅវិមានរដ្ឋសភាជាតិ។ តាមការវាយតម្លៃរបស់ខុមហ្វ្រែលទៅលើសំណួរដែលធ្វើការសាកសួរនេះហាក់បីដូចជាមានលក្ខណៈទូទៅ មិនត្រូវចំណុចដែលប្រជាពលរដ្ឋចង់បាននោះទេព្រោះសំនួរទាំងនោះបានផ្តោតទៅលើ តួនាទី ការងារ និងការវិវត្តន៍របស់ក្រសួងយុត្តិធម៌ដែលមានសេចក្តីទាំងស្រុងថា "អំពីការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៦ តើក្រសួងយុត្តិធម៌មានផែនការសកម្មភាពបែបណាខ្លះទាក់ទិននឹងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដូចជាការកសាងហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន មានសាលាដំបូងខេត្ត រាជធានី សាលាឧទ្ធរណ៍ និងទិសដៅក្នុងការបង្កើតសាលាដំបូងខេត្តកែប ការផ្តល់ជំនួយផ្នែកច្បាប់ និងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ហើយរហូតមកដល់ពេលនេះ បានរៀបចំបង្កើតគ្រប់ខេត្តក្រុង រាជធានីហើយនៅ? ប្រសិនបើនៅតើមានខេត្តណាខ្លះ? អំពីការបណ្តុះបណ្តាលធនធានមនុស្ស តើការពង្រឹងសមត្ថភាពជំនាញដល់មន្ត្រីតុលាការ អយ្យការ និងការលើកកំពស់វិស័យយុត្តិធម៌ និងច្បាប់ពាក់ព័ន្ធ ដើម្បីជំរុញការដោះស្រាយ និងការពង្រឹងយុត្តិធម៌ជូនប្រជាពលរដ្ឋអោយសមស្របនឹងពេលវេលាតាមនីតិវិធីដែលបានកំណត់នៅក្នុងច្បាប់ កិច្ចដំណើរការរបស់តុលាការ អយ្យការ នៅតាមបណ្តាខេត្ត រាជធានី និងការបំពេញតួនាទីរបស់ខ្លួនបានរហើយឬនៅ? ពិសេសការពង្រឹងសមត្ថភាពជំនាញដល់មន្ត្រីតុលាការ អយ្យការតុលាការ តើមានផែនការបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ ដើម្បីបំពេញមុខងាររបស់ខ្លួន អោយមានប្រសិទ្ធិភាពបែបណា?"

សំណួរនេះ មិនបានឆ្លុះបញ្ចាំងអំពីបញ្ហាសង្គម ឬស្ថានភាពដែលបានកើតឡើងចំពោះវិស័យយុត្តិធម៌នៅកម្ពុជានោះទេ។ មានអំពើអយុត្តិធម៌ជាច្រើនដែលបានកើតឡើងនៅក្នុងសង្គមខ្មែរ តែគណៈកម្មការដ្ឋសភាមិនបានផ្តោតទៅលើឡើយ ផ្ទុយទៅវិញក្រោយពីឆ្លើយបំភ្លឺរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មានអ្នកតំណាងរាស្ត្រជាច្រើនរូបបានធ្វើការកោតសរសើរលើការខិតខំប្រឹងប្រែងរបស់ក្រសួងយុត្តិធម៌ ដោយមិនបានលើកឡើងអំពីភាពអយុត្តិធម៌នៅក្នុងសង្គមខ្មែរបច្ចុប្បន្ន។

មានបញ្ហាផ្សេងទៀតដែលបានកើតឡើងក្នុងសង្គមកម្ពុជា ក្រៅពីជម្លោះដីធ្លីរាំរ៉ៃ មានដូចជា ការកាប់បំផ្លាញព្រៃឈើ ការដាក់គុងត្រូលជជុះ ការនាំចូលបន្លែផ្លែឈើ សាច់ដែលខូចគុណភាព និងបញ្ហាពុករលួយផ្សេងៗទៀតដែលកើតឡើង ក៏មិនមានគណៈកម្មការណាមួយកោះហៅរដ្ឋមន្ត្រី ឬតំណាងរាជរដ្ឋាភិបាលដែលទទួលបន្ទុកមកសាកសួរ ឬឆ្លើយបំភ្លឺឡើយ។

កាលពីឆ្នាំ២០១៨កន្លងទៅ តាមរយៈការវាយតម្លៃទាក់ទងនឹងអំពើពុករលួយនៅក្នុងចំណោមប្រទេស១៨០ជុំវិញពិភពលោក ប្រទេសកម្ពុជាស្ថិតនៅចំណាត់ថ្នាក់១៦១ ដែលឈរស្មើ សាធារណរដ្ឋ

ប្រជាធិបតេយ្យកុងហ្គោ និងតាហ្សីគីស្ថាន។[20] តាមរយៈការវាយតម្លៃនេះបានបង្ហាញអោយឃើញថា ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ខ្ពស់ខាងពុករលួយ តែទោះបីជាយ៉ាងនេះក៏ដោយក៏គណៈកម្មការនៃរដ្ឋសភា ជាពិសេសគឺគណៈកម្មជំនាញទី១០ គណៈកម្មការប្រឆាំងអំពើពុករលួយមិនមានសកម្មភាពធ្វើការត្រួតពិនិត្យ និងសិក្សាស្វែងយល់ឡើយ។

## ៤. ការវិភាគសកម្មភាពរបស់តំណាងរាស្ត្រ




ខុមហ្វ្រែលបានជ្រើសរើសសកម្មភាពរបស់តំណាងរាស្ត្រទាំង១០រូប ដែលមានសកម្មភាពសកម្មជាងគេតាមការសង្កេតក្នុងសម័យប្រជុំរដ្ឋសភា និងការចុះមូលដ្ឋាន។ ក្រាហ្វិកខាងលើបានបង្ហាញថា តំណាងរាស្ត្រដែលមានតួនាទីជាសមាជិករដ្ឋាភិបាល ឬតួនាទីក្រៅពីស្ថាប័នរដ្ឋសភាបានចុះបេសកកម្មច្រើនជាងតំណាងរាស្ត្រមិនមែនជាសមាជិករដ្ឋាភិបាល ប៉ុន្តែការបញ្ចេញមតិយោបល់ក្នុងសម័យប្រជុំរដ្ឋសភា ខុមហ្វ្រែល សង្កេតឃើញថា អ្នកដែលមានមុខតំណែងក្នុងរដ្ឋាភិបាលបានបញ្ចេញមតិតិចតួច ឬមិនមានទាល់តែសោះ។ តំណាងរាស្ត្រដែលមានតួនាទីក្នុងរាជរដ្ឋាភិបាល មានដូចជា **សម្តេចក្រឡាហោម ស ខេង** តំណាងរាស្ត្រមណ្ឌលខេត្តបាត់ដំបង ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ **សម្តេចពិជ័យសេនា ទៀ បាញ់** តំណាងរាស្ត្រមណ្ឌលខេត្តសៀមរាប ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ។

[20] ជឿន បញ្ញាឫទ្ធិ, កម្ពុជាជាប់ចំណាត់ថ្នាក់ពុករលួយខ្ពស់ជាងគេក្នុងអាស៊ាន, ការសែតថ្មីថ្មី, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៨ https://thmeythmey.com/?page=detail&id=61995

ឯកឧត្តម កែ គីមយ៉ាន តំណាងរាស្ត្រមណ្ឌលខេត្តបន្ទាយមានជ័យ ជាឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

ខុមហ្វ្រែលសូមដាក់ជាសំណួរចំពោះការវិភាគលើការទំនាក់ទំនងនៃសកម្មភាពដែលបញ្ចេញមតិរបស់តំណាងរាស្ត្រនៅក្នុងសម័យប្រជុំរដ្ឋសភា (មានទាំងការអនុម័តច្បាប់ និងការសម្រេចផែនការផ្សេងៗទៀត) និងសកម្មភាពនៃការចុះមូលដ្ឋាន ដើម្បីជួបជាមួយអាជ្ញាធរ ឬប្រជាពលរដ្ឋ ថាតើវាមានអ្វីទាក់ទងជាមួយគ្នាដែរឬទេ?

នៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ បានលើកឡើងថា តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូលពុំមែនគ្រាន់តែតំណាងប្រជាពលរដ្ឋ ក្នុងមណ្ឌលរបស់ខ្លួននោះទេ (មាត្រា៧៧)។ សម័យប្រជុំរបស់រដ្ឋសភាមានពេលវេលាសម្រាប់វិស្សមកាលរបស់ខ្លួនក្រោយការប្រជុំលើកទី១ និងក្រោយប្រជុំលើកទី២។ រដ្ឋសភាប្រជុំជាសាមញ្ញ ពីរដងក្នុងមួយឆ្នាំ។ សម័យប្រជុំនីមួយៗ មានថិរៈវេលាយ៉ាងតិចបីខែ។ បើមានសំណូមពរ អាចកោះប្រជុំជាវិសាមញ្ញជាបន្ទាន់បាន (មាត្រា៨៣)។

តំណាងរាស្ត្រមានតួនាទីជាអ្នកអនុម័តច្បាប់ និងធ្វើវិសោធនកម្មច្បាប់ (មាត្រា៩០ថ្មីពីរ) ការពិនិត្យមើលសកម្មភាពរបស់រាជរដ្ឋាភិបាល និងអញ្ជើញឥស្សរៈជនមកឆ្លើយបំភ្លឺ(មាត្រា៨៩) ការត្រួតពិនិត្យការអនុវត្តន៍ច្បាប់ ជាដើម ទើបកំឡុងពេលវិស្សមកាល តំណាងរាស្ត្រអាចមានបេសកកម្មចុះជួបជាមួយប្រជាពលរដ្ឋដើម្បីពិនិត្យការប្រឈម ឬការទទួលយកសំណូមពរដែលប្រជាពលរដ្ឋជួបប្រទះ ឬពិនិត្យមើលការអនុវត្តច្បាប់របស់អាជ្ញាធរមូលដ្ឋាន ក្នុងនាមជាអ្នកតំណាងរបស់ពួកគេ ឬជាអ្នកតាក់តែង និងអនុម័តច្បាប់។ ដូច្នេះនៅក្នុងសម័យប្រជុំនៅរដ្ឋសភា អ្នកតំណាងរាស្ត្រតែងតែលើកបញ្ហា ចោទសួរ បកស្រាយចំពោះការប្រឈមផ្លូវច្បាប់ដែលបានអនុម័ត ឬធ្វើការអញ្ជើញមន្ត្រីរបស់រដ្ឋមកសាកសួរពីការអនុវត្តន៍ច្បាប់ ឬឆ្លើយតបពីបញ្ហាអ្វីមួយដែលម្ចាស់ឆ្នោតបានជួបប្រទះ។

ជារួមកិច្ចការទាំងអស់ដែលជជែកដេញដោលគឺតម្រូវឱ្យអ្នកតំណាងរបស់ប្រជាពលរដ្ឋមានការតាមដាន ឬធ្វើការជិតស្និទជាមួយម្ចាស់ឆ្នោត រួមទាំងឆ្លើយតបទៅនឹងប្រយោជន៍ជាសាធារណៈនៃម្ចាស់ឆ្នោតទើបមានតម្លៃជាអ្នកតំណាង និងអាចជជែកដោយមានអំណះអំណាង។

ខុមហ្វ្រែល សូមធ្វើការវិភាគលើអ្នកតំណាងរាស្ត្រ ៥រូប ដែលមានសកម្មភាព ក្នុងសម័យប្រជុំរដ្ឋសភា និងសកម្មភាពចុះមូលដ្ឋាន ដូចខាងក្រោម៖

**១. ឯកឧត្តម ឈាង វុន**៖ ជាតំណាងរាស្ត្រប្រចាំនៅមណ្ឌលខេត្តបាត់ដំបង មិនមានតួនាទីជាសមាជិករដ្ឋាភិបាលនោះទេ។ នៅក្នុងសម័យប្រជុំ ក្នុងឆ្នាំទី១ នៃអាណត្តិទី៦ ខុមហ្វ្រែល បានសង្កេតឃើញថា ឯកឧត្តមបានឡើងបញ្ចេញមតិក្នុងសម័យប្រជុំរដ្ឋសភាមានរយៈពេលសរុបចំនួន ៤៩នាទី ក្នុងនោះ ៤៦នាទី ជាការ

បញ្ចេញមតិក្នុងន័យជាវិជ្ជមាន ដូចជាការសសើរលើរដ្ឋាភិបាលក្នុងការដឹកនាំ ការសសើរលើច្បាប់ដែលរដ្ឋសភាបានអនុម័តជាដើម។ ជាមួយគ្នានេះ បើយើងក្រឡេកទៅមើលពីការចុះមូលដ្ឋានវិញ ខុមហ្វ្រែល សង្កេតឃើញថា ឯកឧត្តមចុះមូលដ្ឋានបាន ៣ដងប៉ុណ្ណោះ ក្នុងនោះ ២ដង ជាសកម្មភាពចុះសួរសុខទុក្ខ និង ១ដង ជាសកម្មភាពអមដំណើរ រីឯសកម្មភាពក្នុងការចូលរួមដោះស្រាយបញ្ហានៅមូលដ្ឋាន ឬការចូលរួមក្នុងវេទិកាគឺមិនឃើញមាននោះទេ។

**២. ឯកឧត្តម ម៉ុក ម៉ារ៉េត៖** ជាតំណាងរាស្ត្រមណ្ឌលខេត្តតាកែវ មិនមានតួនាទីក្នុងរដ្ឋាភិបាលនោះទេ។ នៅក្នុងសម័យប្រជុំឆ្នាំទី១ នៃអាណត្តិទី៦ ខុមហ្វ្រែល បានសង្កេតឃើញថា ឯកឧត្តមបានឡើងបញ្ចេញមតិក្នុងសម័យប្រជុំរដ្ឋសភាមានរយៈពេលសរុបចំនួន ៣១នាទី ជាការបញ្ចេញមតិក្នុងន័យជាវិជ្ជមាន ដូចជាធ្វើការគាំទ្រច្បាប់និងសុំឱ្យក្រសួងអនុវត្តនច្បាប់ឱ្យបានល្អ ឬគុណសម្បត្តិនៃការដឹកនាំរបស់ប្រមុខរដ្ឋាភិបាល។ល។ ជាមួយគ្នានេះ បើយើងក្រឡេកទៅមើលការចុះមូលដ្ឋានវិញ ខុមហ្វ្រែល សង្កេតឃើញថា ឯកឧត្តមចុះមូលដ្ឋានបាន ២៨ដង ក្នុងនោះ ១៩ដងជាសកម្មភាពចុះសួរសុខទុក្ខ ៦ដងជាសកម្មភាពចុះពង្រឹងសមាជិកបក្ស និង៣ដងជាសកម្មភាពអមដំណើរ រីឯសកម្មភាពក្នុងការចូលរួមដោះស្រាយបញ្ហានៅមូលដ្ឋាន ឬការចូលរួមក្នុងវេទិកាគឺមិនឃើញមាននោះទេ។

**៣. ឯកឧត្តម ជា វ៉ាន់ដេត៖** ជាតំណាងរាស្ត្រមណ្ឌលខេត្តតាកែវ មិនមានតួនាទីក្នុងរដ្ឋាភិបាលនោះទេ។ នៅក្នុងសម័យប្រជុំឆ្នាំទី១ នៃអាណត្តិទី៦ ខុមហ្វ្រែល បានសង្កេតឃើញថា ឯកឧត្តមបានឡើងបញ្ចេញមតិក្នុងសម័យប្រជុំរដ្ឋសភាមានរយៈពេលសរុបចំនួន ២៦នាទី ក្នុងនោះការបញ្ចេញមតិក្នុងន័យជាវិជ្ជមាន មានថេរៈវេលាចំនួន ៨នាទី ក្រៅពីនោះក្នុងន័យអព្យាក្រឹតដូចជា ឯកឧត្តមមានមតិគាំទ្រលើច្បាប់ដែលបានអនុម័ត ហើយក្រសួងដែលជាសាម៉ីត្រូវប្រើច្បាប់អោយសមនឹងស្មារតីនៃច្បាប់ ការសំណូមពរអោយក្រសួងពាក់ព័ន្ធនានាជួយពង្រឹងសមត្ថភាពធនធានមនុស្ស។ល។ ជាមួយគ្នានេះ បើយើងក្រឡេកទៅមើលការចុះមូលដ្ឋានវិញ ខុមហ្វ្រែល សង្កេតឃើញថា ឯកឧត្តម ចុះមូលដ្ឋានបាន ២២ដង ក្នុងនោះ ២១ដងជាសកម្មភាពចុះសួរសុខទុក្ខ រីឯសកម្មភាពក្នុងការចូលរួមដោះស្រាយបញ្ហានៅមូលដ្ឋាន ឬការចូលរួមក្នុងវេទិកាគឺមិនឃើញមាននោះទេ។

**៤. សម្តេច ស ខេង៖** ជាតំណាងរាស្ត្រមណ្ឌលខេត្តបាត់ដំបង មានតួនាទីជាឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ នៅក្នុងសម័យប្រជុំក្នុងឆ្នាំទី១ នៃអាណត្តិទី៦ ខុមហ្វ្រែល បានសង្កេតឃើញថា សម្តេចមិនមានការបញ្ចេញមតិក្នុងសម័យប្រជុំរដ្ឋសភានោះទេ ប៉ុន្តែបើយើងក្រឡេកទៅមើលពីការចុះមូលដ្ឋានវិញ ខុមហ្វ្រែល សង្កេតឃើញថា សម្តេចបានចុះមូលដ្ឋានច្រើនរហូត ៩៤ដង ក្នុងនោះ ៥៤ដងជាសកម្មភាពចុះសួរសុខទុក្ខ ៣៤ដងជាសកម្មភាពចុះអមដំណើរ និង ៦ដងជាការចុះពង្រឹងបក្ស រីឯសកម្មភាពក្នុងការចូលរួមដោះស្រាយបញ្ហានៅមូលដ្ឋាន ឬការចូលរួមក្នុងវេទិកាគឺមិនឃើញមាននោះទេ។

**៥. សម្តេច ទៀ បាញ់៖** ជាតំណាងរាស្ត្រមណ្ឌលខេត្តសៀមរាប ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ។ នៅក្នុងសម័យប្រជុំឆ្នាំទី១ នៃអាណត្តិទី៦ ខុមហ្វ្រែល បានសង្កេតឃើញថា សម្តេចមិនមានការបញ្ចេញមតិក្នុងសម័យប្រជុំរដ្ឋសភានោះទេ ប៉ុន្តែបើយើងក្រឡេកទៅមើលការចុះមូលដ្ឋានវិញ ខុមហ្វ្រែលសង្កេតឃើញថា សម្តេចបានចុះមូលដ្ឋានច្រើនគឺ ៧៧ដង ក្នុងនោះ ៣៤ដងជាសកម្មភាពចុះសួរសុខទុក្ខ ៣៩ដងជាសកម្មភាពចុះអមដំណើរ និង ៤ដងជាការចុះពង្រឹងបក្ស រីឯសកម្មភាពក្នុងការចូលរួមដោះស្រាយបញ្ហានៅមូលដ្ឋាន ឬការចូលរួមក្នុងវេទិកាគឺមិនឃើញមាននោះទេ។

## ៥. រដ្ឋសភាឯកបក្ស

សវនាការតុលាការកំពូលបានរំលាយគណបក្សសង្គ្រោះជាតិ និងព្យួរសិទ្ធិនយោបាយថ្នាក់ដឹកនាំបក្សនេះចំនួន ១១៨រូប រយៈពេល៥ឆ្នាំ ទៅតាមពាក្យបណ្តឹងរបស់ក្រសួងមហាផ្ទៃ កាលថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧។ ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឆ្នាំ២០១៨ នៃនីតិកាលទី៦នេះ មានគណបក្សនយោបាយចំនួន២០ បានចូលរួមប្រកួតប្រជែងឈរឈ្មោះបោះឆ្នោតជាតំណាងរាស្ត្រ។ ក្រោយការបោះឆ្នោតថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ រដ្ឋសភាគ្មានគណបក្សណាមួយក្រៅតែពីគណបក្សប្រជាជនកម្ពុជាតែមួយប៉ុណ្ណោះ ដែលមានអាសនៈ និងកៅអីនៅក្នុងរដ្ឋសភារហូតទៅដល់ ១២៥អាសនៈដែលស្មើនិង ១០០% នៃអាសនៈតំណាងរាស្ត្រទាំងអស់។

ចំពោះការចូលរួមសម័យប្រជុំពេញអង្គទាំងសាមញ្ញសាធារណៈ និងវិសាមញ្ញសាធារណៈក្នុងរដ្ឋសភា ក្នុងឆ្នាំទី១ នៃនីតិកាលទី៦នេះ ខុមហ្វ្រែលសង្កេតឃើញថារដ្ឋសភាមិនមានរឿងចម្រូងចម្រាសដូចមុនៗនោះទេ។ អាណត្តិមុនៗដែលមានគណបក្សប្រឆាំងមានអាសនៈក្នុងរដ្ឋសភា តំណាងរាស្ត្រទាំងនោះបានចូលរួម ផ្តល់ជាគំនិត មតិយោបល់ ឬជំទាស់ទៅលើការអនុម័តច្បាប់ ការបង្កើតច្បាប់ ឬវិសោធនកម្មច្បាប់ដែលយល់ឃើញថាមានចំណុចចន្លោះប្រហោង ដែលនាំឱ្យដំណើរការជជែកមានមានការរាំងស្ទះខ្លះ[21]។

តាមការសង្កេតកន្លងមក បញ្ហាដែលអាចមានការរាំងស្ទះនោះគឺវាមានការពាក់ព័ន្ធជាមួយការអនុវត្តិគោលនយោបាយថវិកាជាតិ វិសោធនកម្មច្បាប់ និងច្បាប់នានា ដែលរដ្ឋសភាបានលើកយកមកពិភាក្សា។ កាលគណបក្សសង្គ្រោះជាតិមិនទាន់រំលាយ តំណាងរាស្ត្រដែលមកពីគណបក្សសង្គ្រោះជាតិតែងតែលើកជាទស្សនៈ និងបញ្ចេញមតិយោបល់ជំទាស់ ហើយបានរិះគន់ទៅលើកិច្ចពិភាក្សានានានៅក្នុងសម័យប្រជុំពេញអង្គតែម្តង ព្រោះសមាជិករបស់គណបក្សសង្គ្រោះជាតិតែងលើកថា ការអនុម័តច្បាប់ និងការអនុវត្តិផ្សេងៗ មិនត្រឹមត្រូវ លឿនពេក មិនមានភាពយុត្តិធម៌ ហើយថែមទាំងជះឥទ្ធិពលអាក្រក់ទៅដល់ផលប្រយោជន៍ជាតិ និងផលប្រយោជន៍ប្រជាជនទាំងមូលផងដែរ។

[21] នីតិកាលទី៦នេះ មានគណៈបក្សប្រជាជនកម្ពុជាតែមួយគត់ដែលមានអាសនៈ១២៥នៅក្នុងរដ្ឋសភា

ផ្ទុយមកវិញនៅក្នុងអាណត្តិទី៦នេះ មានតែគណបក្សប្រជាជនកម្ពុជាតែមួយប៉ុណ្ណោះដែលចេញចូលប្រជុំក្នុងរដ្ឋសភា និងគ្រប់គ្រងគណៈកម្មការទាំងអស់របស់រដ្ឋសភា រួមទាំងការគ្រប់គ្រងស្ថាប័នរដ្ឋ នោះមានន័យថាគណបក្សប្រជាជនកម្ពុជា ដឹកនាំទាំងស្ថាប័ននីតិបញ្ញត្តិ និងនីតិប្រតិបត្តិ។

នៅក្នុងអំឡុងពេលរដ្ឋសភាបើកកិច្ចប្រជុំនីមួយៗ តាមការសង្កេតរបស់ខុមហ្វ្រែលបានមើលឃើញថា មិនសូវមានការសួរដេញដោលគ្នា ឬមានភាពផុសផុលក្នុងការតតាំងគ្នាឡើយ។ កិច្ចប្រជុំម្តងៗ តែងប្រព្រឹត្តទៅដោយរលូន ហើយការពិភាក្សាគ្នាពីច្បាប់ផ្សេងៗ តែងឈានទៅដល់ការអនុម័តដោយងាយស្រួល ដោយមិនមានការជំទាស់ ឬធ្វើការវែកញែក ពិភាក្សាគ្នា ដូចជាកាលនៅមានគណបក្សប្រឆាំងនោះឡើយ។

## ៥.១. នីតិកាលទី៦ រដ្ឋសភាមិនមានការចម្រូងចម្រាស

នៅក្នុងប្រទេសប្រកាន់យកលទ្ធិប្រជាធិបតេយ្យ រដ្ឋសភាដែលជាអង្គនីតិប្បញ្ញត្តិ ឬជាស្ថាប័នតាក់តែងច្បាប់ មានតួនាទីសំខាន់ខ្លាំងណាស់ក្នុងការជួយធ្វើអោយសង្គមជាតិស្អាតស្អំ គ្មានអំពើពុករលួយ និងលើកស្ទួយទៅដល់ការគោរពច្បាប់។ រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា មាត្រា៩៦ ក៏បានបង្ហាញពីតួនាទីរបស់តំណាងរាស្ត្រដែរថា រដ្ឋសភាអាចសម្រេចគោលដៅទាំងនេះបាន តាមរយៈការធ្វើច្បាប់ តាមដានរាល់សកម្មភាពនៃការអនុវត្តច្បាប់របស់រាជរដ្ឋាភិបាល និងកោះហៅមន្ត្រីរដ្ឋាភិបាលមកឆ្លើយបំភ្លឺជាដើម។

រដ្ឋសភា ជាស្ថាប័នជាតិកំពូលមួយក្នុងចំណោមស្ថាប័នកំពូលទាំងបី។ ស្ថាប័នកំពូលពីរទៀត មានរាជរដ្ឋាភិបាល និងតុលាការ។ រដ្ឋធម្មនុញ្ញកម្ពុជាកំណត់អោយស្ថាប័នទាំងបីនេះបែងចែកអំណាចដាច់ពីគ្នា និងប្រកាន់យកប្រព័ន្ធនយោបាយសភានិយម ដែលរដ្ឋសភាមានតួនាទី និងអំណាចធំសម្បើម។ អំណាចទាំងនោះរួមមាន ត្រួតពិនិត្យសកម្មភាពរបស់រដ្ឋាភិបាល រហូតដល់អាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលទាំងមូលទៀតផង។

សមាជិករដ្ឋសភាត្រូវបានបោះឆ្នោតជ្រើសតាំងដោយផ្ទាល់ពីប្រជាពលរដ្ឋ រៀងរាល់៥ឆ្នាំម្តង។ រដ្ឋសភាមានតួនាទីសំខាន់បី៖ ការធ្វើច្បាប់ យល់ព្រមលើគោលនយោបាយជាតិ និងត្រួតពិនិត្យមើលរាជរដ្ឋាភិបាល។ ខណៈដែលសមាជិករដ្ឋសភាអាចផ្តួចផ្តើមសេចក្តីស្នើច្បាប់ រដ្ឋសភាក៏ជាអ្នកអនុម័តសេចក្តីព្រាងច្បាប់ ផ្តួចផ្តើមដោយក្រសួងសាមី ឬនាយករដ្ឋមន្ត្រីប្រមុខនៃអំណាចនីតិប្រតិបត្តិផងដែរ។ ផែនការ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាយុទ្ធសាស្ត្រ ព្រមទាំង ថវិកាជាតិ ត្រូវដាក់ឆ្លងសុំការយល់ព្រមពីរដ្ឋសភា។ ជាពិសេសរដ្ឋសភាមានអំណាចត្រួតពិនិត្យមើលរាជរដ្ឋាភិបាល និងសមាជិករាជរដ្ឋាភិបាល ដែលជាអ្នកទទួលខុសត្រូវនៅចំពោះមុខរដ្ឋសភាអំពីការអនុវត្តច្បាប់ និងគោលនយោបាយ។

នៅក្នុងឆ្នាំទី១ នីតិកាលទី៦ ក្រោយការរំលាយគណបក្សប្រឆាំងដ៏ធំនៅកម្ពុជា និងជាដៃគូប្រកួតប្រជែងផ្នែកនយោបាយជាមួយគណបក្សកាន់អំណាច តាមការអង្កេតរបស់ខុមហ្វ្រែលឃើញថា ភាពធូរលុងនៃការអនុម័តច្បាប់នៅតែខ្វះចន្លោះ ត្រង់ថានៅក្នុងនីតិកាលទី៦នេះ រាល់ការអនុម័តច្បាប់នានា និងវិសោធនកម្ម មានភាពងាយស្រួលទៅដល់គណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សកាន់អំណាច ជាពិសេសទាក់ទងនឹងច្បាប់សំខាន់ៗ និងការការពារផលប្រយោជន៍ប្រជាជន។ សម្រាប់ការអនុម័តច្បាប់ម្ត

ងៗ តំណាងរាស្ត្រដែលបានចូលរួមតាមសម័យប្រជុំ តែងតែលើកដៃបង្ហាញពីការគាំទ្រ ដោយមិនមានការលើកជំទាស់ពីគណៈកម្មការជំនាញ និងតំណាងរាស្ត្រណាមួយនោះឡើយ។

សម្រាប់បរិយាកាសខាងក្រៅ កម្ពុជាបានកំពុងដើរថយពីរដ្ឋធម្មនុញ្ញ ទោះបីក្នុងស្ថានភាពនេះ មិនមានវត្តមានគណបក្សប្រឆាំងណាមួយនៅក្នុងរដ្ឋសភាក៏ដោយ ចំពោះរដ្ឋសភាជាតិវិញ មិនត្រឹមតែមិនបានប្រើប្រាស់អំណាចរបស់ខ្លួនអោយសមត្រឹមត្រូវតាមគន្លងប្រជាធិបតេយ្យ ដែលរដ្ឋធម្មនុញ្ញបានប្រគល់អំណាចអោយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្លាយទៅជាស្ថាប័នចាំតែប្រថាប់ត្រា ឬសម្រួលកិច្ចការជាប្រយោជន៍នយោបាយជូនដល់រាជរដ្ឋាភិបាលកម្ពុជាទៅវិញ។ ម្យ៉ាងទៀត រដ្ឋសភាឯកបក្សគ្មានការជជែកវែកញែក សួរដេញដោលច្បាប់នានា ពេលប្រជុំនៅក្នុងរដ្ឋសភានីមួយៗ និងបេសកកម្មសុខទុក្ខប្រជាពលរដ្ឋតាមខេត្ត រាជធានី ដូចកាលមានវត្តមានគណបក្សប្រឆាំងឡើយ។

## ៦. កាលប្បវត្តិព្រឹត្តិការណ៍សំខាន់ៗ នៃរដ្ឋសភាជាតិ

### សម័យប្រជុំលើកទី១ នីតិកាលទី៦
### (ចន្លោះពីខែកញ្ញា ឆ្នាំ២០១៨ ដល់ខែសីហា ឆ្នាំ២០១៩)

- **ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ២០១៨ រដ្ឋសភាបានបើកសម័យប្រជុំ អនុម័តរបៀបវារៈចំនួន១៖**

  ១.ធ្វើការសម្រេចអំពីសុពលភាពនៃអាណត្តិរបស់បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រចំនួន៣៦រូប។
- **ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០១៨ រដ្ឋសភាបានបើកសម័យប្រជុំ អនុម័តរបៀបវារៈចំនួន០៤៖**

  ១. ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។

  ២.ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិការទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧។

  ៣. ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើ

  ក. កិច្ចព្រមព្រៀងរវាងកម្ពុជា និងវៀតណាមស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបកេងបន្លំពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។

  ខ. ការព្រមព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូណេស៊ី ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបកេងបន្លំពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។

  ៤. ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី។

**ចន្លោះពីខែមករា ដល់ខែសីហា ឆ្នាំ២០១៩ (សម័យប្រជុំលើកទី២ នីតិកាលទី៦)**

- **ថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩ រដ្ឋសភាបានបើកសម័យប្រជុំ អនុម័តរបៀបវារៈចំនួន០៤៖**

  ១. ព្រះរាជសារព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

២.របាយការណ៍សកម្មភាពរបស់រដ្ឋសភាចន្លោះសម័យប្រជុំរដ្ឋសភាលើកទី១និងលើកទី២នីតិកាលទី៦។

៣. ការបោះឆ្នោតជ្រើសតាំង លោកជំទាវ លី វួចឡេង ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញសម្រាប់អាណត្តិឆ្នាំ ២០១៩ ២០២៨។

៤. ការបោះឆ្នោតជ្រើសតាំង

ក. ឯកឧត្តម ប្រាជ្ញ ច័ន្ទ ជាសមាជិកគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា និងព្រឹទ្ធសភា។

ខ.ឯកឧត្តម ច័ន្ទ សុផល ជាសមាជិកគណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ។

- **ថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៩ រដ្ឋសភាបានបើកសម័យប្រជុំ អនុម័តរបៀបវារៈចំនួន០៥៖**

១. សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាអោយក្រុមហ៊ុនអេសភីអេលភី( ខេមបូឌា ) ឯ.ក។

២. សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាអោយក្រុមហ៊ុនស្នេថេករីញូវេប៊ិលឯ.ក។

៣. សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាអោយក្រុមហ៊ុនស្នេថេក ខូអិលធីឌី។

៤. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមអោយព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិកនៃកិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។

៥. សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៩ ដល់២០២៣។

- **ពីថ្ងៃទី០១ ខែមិនា ឆ្នាំ ២០១៩ រដ្ឋសភាបានបើកសម័យប្រជុំ អនុម័តរបៀបវារៈចំនួន០៣៖**

១. ការពិភាក្សា និងអនុម័តសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ។

២. ការពិភាក្សា និងអនុម័តសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

៣. សេក្តីស្នើច្បាប់ស្តីពីវិសោធនកម្មមាត្រា ៤៥ថ្មី (ស្ទួន) នៃច្បាប់ស្តីពីគណបក្សនយោបាយ។

- **ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៩ រដ្ឋសភាបានបើកសម័យប្រជុំ អនុម័តរបៀបវារៈចំនួន០១៖**

១. ឆ្លើយសំនួរៈ ក្នុងការអនុវត្តន៍យុទ្ធសាស្រ្តចតុកោណតំណាក់កាលទី ៤ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី០៦ តើក្រសួងយុត្តិធម៌មានផែនការសកម្មភាពបែបណាខ្លះទាក់ទិនកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដូចជា ការកសាងហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន មានសាលាដំបូងខេត្ត រាជធានីសាលាឧទ្ធរណ៍ និងទិសដៅក្នុងបង្កើតសាលាដំបូងខេត្តកែប ការផ្តល់ជំនួយផ្នែកច្បាប់ និងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាកា រហូតមកដល់ពេលនេះ បានរៀបចំបង្កើតគ្រប់ខេត្តក្រុង រាជធានីហើយនៅ ប្រសិនបើនៅតើមានខេត្តណាខ្លះ? អំពីការបណ្តុះធនធានមនុស្ស

តើការពង្រឹងសមត្ថភាពជំនាញដល់មន្ត្រីតុលាការ អយ្យការ និងការលើកកម្ពស់វិស័យយុត្តិធម៌ និងច្បាប់ពាក់ព័ន្ធ ដើម្បីជំរុញការដោះស្រាយ និងពង្រឹងយុត្តិធម៌ជូនប្រជាពលរដ្ឋ អោយសមស្របនឹងពេលវេលវេលា តាមនីតិវិធីដែលបានកំណត់នៅក្នុងច្បាប់ កិច្ចដំណើរការរបស់តុលាកា អយ្យការនៅតាមបណ្តាខេត្ត រាជធានី និងការបំពេញតួរនាទីរបស់ខ្លួនបានហើយឬនៅ ពិសេសការពង្រឹងសមត្ថភាពជំនាញដល់មន្ត្រីតុលាការ និងអយ្យការតុលាការ? តើមានផែនការបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ ដើម្បីបំពេញមុខងាររបស់ខ្លួនអោយមានប្រសិទ្ធភាពបែបណា?

- **ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ រដ្ឋសភាបានបើកសម័យប្រជុំ អនុម័តរបៀបវារៈចំនួន០៦៖**

១. ការសម្រេចអំពីសុពលភាពនៃអាណត្តិរបស់ឯកឧត្តម សុខ ផេង ជាតំណាងរាស្ត្រមណ្ឌលខេត្តព្រៃវែង។

២. ការពិភាក្សា និងអនុម័តសេចក្តីព្រៀងច្បាប់ស្តីពី ការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត។

៣. ការពិភាក្សា និងអនុម័តសេចក្តីព្រៀងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដេស ស្តីពីការជំរុញនិងការការពារទៅវិញទៅមកនៃវិនិយោគ។

៤. ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងសហភាពអារ៉ាប់មីរ៉េត ស្តីពីការជំរុញនិងការការពារទៅវិញទៅមកនៃវិនិយោគ។

៥. ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋទួកគី ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃការវិនិយោគ។

៦. ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គការបណ្តាញអន្តរជាតិសម្រាប់ឬស្សី និងផ្តៅ។

- **ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ រដ្ឋសភាបានបើកសម័យប្រជុំ អនុម័តរបៀបវារៈចំនួន០១៖**

១. ការបោះឆ្នោតជ្រើសតាំងឯកឧត្តម អ៊ិត រ៉ាឌី ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រាប់អាណត្តិថ្មី ជ្រើសតាំងដោយរដ្ឋសភានីតិកាលទី០៦។